## បន្ទីរកសិកម្មខេត្តកណ្ដាល

# ផលិតកម្ម
# ដំណាំពោត

ឆ្នាំ២០១៥

# សៀវភៅណែនាំ
# ផលិតកម្មដំណាំពោត

រៀបចំដោយមន្ទីរកសិកម្មខេត្តកណ្តាល

## អ្នករៀបរៀង

លោក អ៊ិន ចាន់យ៉ារិទ្ធ

## អ្នកផ្តល់យោបល់ និង កែសម្រួល

លោក ប៊ុនធូន ស៊ីមូណា

លោក លឹម ងួនគ្រុយ

លោក ហ៊ី សុផល

លោក ឡុង រ៉ា

លោក ផា ថាម

លោក ប៉ាន់ ខេមរិន្ទ

លោក ហាស់ វុទ្ធី

លោក អាង វណ្ណា

ម.ព.ឯ.ក AIDOC
Code: 119-014
Date:
Donated by:

# មាតិកា

**១.សេចក្តីផ្តើម** ........ ០១

១.១-ប្រវត្តិដំណាំពោត ........ ០១

១.២-ស្ថានភាពដំណាំពោតនៅប្រទេសកម្ពុជា ........ ០១

១.៣-ស្ថានភាពដំណាំពោតនៅក្នុងពិភពលោក ........ ០២

១.៤-សារៈប្រយោជន៍ នៃដំណាំពោត ........ ០៤

**២. លក្ខណៈរូបសាស្ត្រនៃដំណាំពោត** ........ ០៦

២.១-ប្រព័ន្ធឬស ........ ០៦

២.២-ស្លឹក ........ ០៦

២.៣-ដងដើម ........ ០៧

២.៤-ផ្កា ........ ០៨

២.៥-ផ្លែ ........ ០៩

**៣. ដំណាក់កាលលូតលាស់របស់ដំណាំពោត** ........ ០៩

៣.១-ចាប់ពីពេលដាំរហូតដល់ពន្លកស្លឹក ........ ០៩

៣.២-ពន្លកស្លឹករហូតដល់ពេលចេញផ្កា ........ ១០

៣.៣-ពេលចេញផ្ការហូតដល់ពេលចេញផ្លែ ........ ១០

៣.៤-ពេលលូតលាស់ផ្លែ ........ ១១

៣.៥-ពេលទុំ ........ ១២

**៤.តម្រូវការសារធាតុចិញ្ចឹមសម្រាប់ដំណាំពោត** ........ ១២

**៥-តម្រូវការទឹកសម្រាប់ដំណាំពោត** ........ ១៤

**៦-បច្ចេកទេសដាំដុះ និង ការថែទាំ** ........ ១៤

៦.១ រដូវកាលដាំដុះ ........ ១៤

AIDC
Donated by

៦.២-ការរៀបចំដី............................................................ ១៥
៦.៣-ការដាំដុះ និង ថែទាំ ....................................................១៧
៦.៤-ការដាក់ជី....................................................................១៩
**៧-ការកម្លាត់ស្មៅ**........................................................................២១
**៨-ជម្ងឺ និងសត្វល្អិតចង្រៃ**.........................................................២២
**៨.១ ជម្ងឺ**.................................................................................២២
៨.១.១ ជម្ងឺរលួយគ្រាប់ពោត...................................២២
៨.១.២ ជម្ងឺស្លោកស្លឹកលើកូនពោត............................២២
៨.១.៣ ជម្ងឺរលួយគល់...............................................២៤
៨.១.៤ ជម្ងឺអុចស្លឹកពោត(ភ្នែកចាប) ..........................២៥
៨.១.៥ ជម្ងឺផ្សិតខ្មៅ.....................................................២៦
៨.១.៦ ណេម៉ាតូថ..........,,,,,,........................................២៧
៨.១.៧ ជម្ងឺច្រេះស្លឹក...................................................២៨
៨.១.៨ ជម្ងឺពុកដើម....................................................២៩
៨.១.៩ ជម្ងឺរលួយផ្សិត.................................................៣០
៨.១.១០ ជម្ងឺស្រពោនបណ្ដាលមកពីផ្សិត.......................៣០
៨.១.១១ ជម្ងឺអុចត្នោត................................................៣២
៨.១.១២ ជម្ងឺរលួយផ្លែ និងដើម....................................៣៣
៨.១.១៣ ជម្ងឺផ្សិតរលួយគ្រាប់......................................៣៤
៨.១.១៤ ជម្ងឺតុងគ្រោ....................................................៣៥
៨.១.១៥ ជម្ងឺគៀក្រិន...................................................៣៦

៨.១.១៦ ជម្ងឺតៀលៀង..........................................៣៧

៨.១.១៦ ជម្ងឺរីងស្លឹក..............................................៣៨

**៨.២ សត្វល្អិតចង្រៃ**................................................ ៣៩

៨.២.១ ដង្កូវរុយចោះគ្រាប់ពោត...............................៣៩

៨.២.២ ចៃ........................................................................ ៤០

៨.២.៣ដង្កូវហ្វូង.............................................................. ៤៤

៨.២.៤ ដង្កូវចោះផ្លែពោត............................................. ៤៦

៨.២.៥ ដង្កូវស៊ីរូងដើម....................................................៤៩

៨.២.៦ ខ្មូតខ្មៅអុចលឿង...............................................៥២

៨.២.៧ ទាកគូពោត........................................................ ៥៣

៨.២.៨ ទ្រីប ឬ មមង់ជញ្ជក់ជ័រ................................... ៥៥

៨.២.៩ ដង្កូវជ្ញូង.............................................................. ៥៦

**៩. ការប្រមូលផល និង ទុកដាក់** ...............................៥៧

៩.១ ការច្រូតកាត់ប្រមូលផល................................... ៥៧

៩.២ ការទុកដាក់គ្រាប់ពូជ..........................................៦០

ឯកសារយោង.................................................................. ៦១

# ដំណាំពោត

## Zea may

## ១-សេចក្ដីផ្ដើម

### ១.១.ប្រវត្តិដំណាំពោត




ដំណាំពោត មានប្រភពដើមនៅទ្វីបអាមេរិកកណ្ដាល គឺនៅក្នុងប្រទេសម៉ិចសិក ដោយនៅតំបន់ទាំងនោះ គេសង្កេតឃើញមានកំទេចកំទី ដែលជាភស្ដុតាងនៃដំណាំពោតនេះ តាំងពី៥០០០ឆ្នាំមុន គ.ស ។

-ចាប់ពីឆ្នាំ១៥៤៣ ដំណាំពោតត្រូវបានគេនាំចូលដល់បណ្ដាប្រទេសនានានៅទ្វីបអឺរ៉ុបដោយពួកនាវាចរអេស្ប៉ាញ៉ុល។

-នៅចុងសតវត្សទី១៥ និងដើមសតវត្សទី១៦ដំណាំពោតបានរីកសាយពេញទ្វីបអាហ្វ្រិក, ប្រទេសឥណ្ឌា, ចិន, ភូមា, ជប៉ុន និង នៅអំឡុងសតវត្សទី១៧-១៨ ដំណាំនេះក៏បាននាំចូលមកដល់ប្រទេសកម្ពុជាយើង។

### ១.២.ស្ថានភាពដំណាំពោតនៅប្រទេសកម្ពុជា

នៅប្រទេសកម្ពុជាដំណាំពោត ត្រូវបាននាំចូលក្នុង

សម័យអាណានិគមបារាំង សតវត្សទី"១៧-១៨" ។ ដំណាំនេះ បានឈានឡើងដល់ចំណាត់ថ្នាក់ជាតិនៅក្នុងឆ្នាំ១៩១០។ ក្នុងឆ្នាំ១៩៣៦-១៩៣៧ ប្រទេសកម្ពុជាបានផលិតគ្រាប់ពោតចំណីដល់កំរិតមួយខ្ពស់បំផុត រហូតដល់ទៅ៤០០០០០តោន លើផ្ទៃដីប្រមាណ២៥០ពាន់ហិកតា។

## ១.៣.ស្ថានភាពដំណាំពោតនៅក្នុងពិភពលោក

-ពោតជាចំណីអាហារមួយចាំបាច់សម្រាប់ មនុស្ស, សត្វ និងការកែច្នៃក្នុងវិស័យឧស្សាហកម្ម។ នៅប្រទេសម៉ិចសិក និងនៅបណ្តាប្រទេសនៅទ្វីបអាមេរិកខាងត្បូង ឥណ្ឌា និងប្រទេសមួយចំនួននៅអាហ្វ្រិក បានបរិភោគពោតជាចំណីអាហារចំបាច់ប្រចាំថ្ងៃ។

-នៅតាមប្រទេសនៅអាស៊ី ពោតត្រូវបានប្រើប្រាស់សំខាន់សម្រាប់ជាចំណីសត្វពិសេសនៅប្រទេសជប៉ុន, កូរ៉េ, ថៃ, ចិន បានប្រើប្រាស់គ្រាប់ពោតសម្រាប់ផ្សំធ្វើជាចំណីសត្វ។

-ពោត (Maize) ជាដំណាំទី១ ដែលដាំដុះច្រើនជាងគេនៅលើពិភពលោកដែលលើសពីដំណាំស្រូវសាឡី (Wheat) និងដំណាំស្រូវ (Rice) ។ ក្នុងឆ្នាំ២០០០ផលិតកម្មដំណាំពោតនេះបានកើនឡើង រហូតដល់៥០០លានតោនក្នុង១ឆ្នាំ។



ពោតផ្អែម



ពោតក្រហម



ពោតដំណើប



ពោតរឹង



## ១.៤.សារៈប្រយោជន៍ នៃដំណាំពោត

**១.៤.១ សុខភាព៖** តាមការសិក្សាមួយបានបង្ហាញថា ពោតមិនត្រឹមតែជាដំណាំស្បៀងយ៉ាងសំខាន់ បន្ទាប់ពីដំណាំស្រូវប៉ុណ្ណោះទេ វាក៏ជាចំណីអាហារឆ្ងាញ់ដែលយើងអាចយកវាច្នៃជាម្ហូប ឬយកទៅធ្វើបង្អែមក៏បាន។ ពិសេសជាងនេះទៅទៀតនោះពោតបានផ្ដល់សារធាតុចិញ្ចឹមជាច្រើនដល់រាងកាយ។

ក.សារធាតុប្រឆាំងអុកស៊ីតកម្ម

ពោតមានសារធាតុប្រឆាំងអុកស៊ីតកម្មជាច្រើនដូចជា: Phytonutrients និង Carotenoids ជាដើម (ជាពិសេសនៅក្នុងពោតពណ៌លឿង) ។ ក្រៅពីនេះនៅមានសារធាតុផ្សេងទៀតដូចជា Lutein, Zeaxanthin, អាស៊ីត Vanillic, អាស៊ីត Ferulic និងសារធាតុប្រឆាំងអុកស៊ីតកម្មមួយចំនួនទៀត។

ខ.កាបូអ៊ីដ្រាត

ពោតផ្ដល់សារធាតុកាបូអ៊ីដ្រាត ជាថាមពលដែលរាងកាយត្រូវការជាប្រចាំថ្ងៃសម្រាប់សកម្មភាព រាងកាយ និងខួរក្បាល ម្យ៉ាងវាក៏ផ្ដល់កម្លាំងទៅដល់រាងកាយផងដែរ ជាពិសេសអ្នកអត្តពលកម្ម។

គ.ប្រូតេអ៊ីន

ផ្លែពោតមានផ្ទុកសមាសធាតុប្រូតេអ៊ីន ដែលជាសារធាតុចិញ្ចឹមសារពាង្គកាយ ហើយរាងកាយក៏ត្រូវការវាជាចាំបាច់ផងដែរ។ ប្រូតេអ៊ីនក៏អាចជួយជួសជុលកោសិកា ជួយសាច់ដុំ និងបង្កើនប្រព័ន្ធភាពស៊ាំ។

ឃ.សារធាតុមិនធ្វើឲ្យធាត់ខ្លាំង

ពោតមានសារធាតុល្អសម្រាប់សុខភាព ហើយម្យ៉ាងវាក៏មានសារធាតុដែលធ្វើឲ្យយើងមិនឡើងទម្ងន់ខ្លាំងផងដែរ។

ង.ជាតិសរសៃ(Fiber)

នៅក្នុងផ្លែពោតមានសារជាតិសរសៃ(Fiber) ដែលល្អសម្រាប់សុខភាព។ ម្យ៉ាងទៀតវាក៏មានសារធាតុម្យ៉ាងដែលជួយរក្សាកម្រិតជាតិស្ករក្នុងឈាម និងជួយបង្ការរោគទល់លាមកផងដែរ។ ទន្ទឹមនឹងនេះបរិភោគផ្លែពោតអាចធ្វើឲ្យឆ្អែតបានយូរ៕

**១.៤.២ អាហារ៖**

-ជាចំណីអាហារប្រចាំថ្ងៃសម្រាប់មនុស្សនៅអាមេរិកខាងត្បូងនិងអាហ្វ្រិក

-ជាចំណីអាហារបន្ថែម

-ជាចំណីអាហារសម្រាប់សត្វ

**១.៤.៣ វត្ថុធាតុដើម ៖**

-ធ្វើជាម្សៅក្រដាស

-ធ្វើជាជ័រកាវ

-ធ្វើជាគ្រឿងតម្បាញ

-ធ្វើជាម្សៅអាមីដុង

-ធ្វើជាសាប៊ូ

-ធ្វើជាទឹកស៊េរ៉ូ

-ធ្វើជាជាគ្រឿងផ្សំសម្រាប់ការផលិតឱសថ

## ២- លក្ខណៈរូបសាស្ត្រនៃដំណាំពោត

ពោតជាដំណាំមួយ ដែលមានឈ្មោះវិទ្យាសាស្ត្រ **Zea mays** ដែលស្ថិតនៅក្នុងគ្រួសារ **Poaceae** ដំណាំនេះមានប្រភពដើមពីអាមេរិកកណ្តាល(**Mexico and Guatemala**) ដែលមនុស្សធ្លាប់ស្គាល់តាំងពី៧០០០ឆ្នាំមុន។

### ២.១-ប្រព័ន្ធឫស

ពោតជារុក្ខជាតិមួយដែលគ្មានឫសកែវ ។ ឫសពោតកើតឡើងដុះចេញពីថ្នាំងនៅក្នុងដី ដែលជាប្រភេទឫសរយាង ហើយក៏គេអាចឃើញមានឫស ដែលដុះចេញពីថ្នាំងនៅលើដីដែរ ហើយឫសនោះអាចចាក់ចុះដល់ដី នៅពេលដែលយើងពូនគល់ ។

រូបសណ្ឋាននៃឫសពោតមានរាងជាសរសៃ ដែលមានទំហំប្រមាណ០,៥ម.ម ទៅ២ម.ម នឹងមានប្រវែងដែលអាចចាក់ចូលក្នុងដីបានជម្រៅពី២០-៣០ស.ម (ដែលមានប្រមាណ៨០% នៃប្រព័ន្ធឫស) ហើយបើករណីដីធូរអាចចាក់ចូលក្នុងបានរហូតដល់ទៅជម្រៅ១ម៉ែត្រ។

### ២.២-ស្លឹក

ស្លឹកពោតមានរាងទ្រវែង ធំទូលាយ និង ចុងស្រួច។ លើផ្ទៃស្លឹកមានទ្រនង់កណ្តាលបណ្តោយស្លឹកធំមួយ និងទ្រនង់

តូចៗជាច្រើនតាមបណ្តោយផ្ទៃស្លឹក ។ ស្លឹកនិមួយៗដុះចេញពីដងដើមត្រង់ថ្នាំង ហើយឆ្លាស់គ្នាពីស្លឹកមួយទៅស្លឹកមួយ។ ស្លឹកចែកចេញជាបីផ្នែកគឺ:ស្រទបស្លឹក ដែលអោបដងដើម អណ្តាតស្លឹក និង តួស្លឹក ។

ដើមពោតមួយដើម ជាមធ្យមអាចមានស្លឹកចំនួនពី១២ ដល់១៨ស្លឹក។ ផ្ទៃស្លឹកជាទូទៅមានទទឹងប្រមាណពី១០ទៅ ១៥ សម និង បណ្តោយប្រមាណ១០០សម ។

## ២.៣-ដងដើម

ជាទូទៅដំណាំពោត មានដងដើមតែមួយប៉ុណ្ណោះក្នុងពោតមួយគ្រាប់ដែលយើងបានដាំ។ ដើមពោតពេលបច្ចុប្បន្ននេះ ជាទូទៅមិនបែកគុម្ពឡើយ លើកលែងតែជាប្រភេទពោតព្រៃទើបគេជួបប្រទះមានបែកគុម្ព។ ដងដើមពោតជាទូទៅមានកំពស់ពី៥០ ស.ម ទៅ ៣០០ ស.ម ដោយយោងទៅតាមប្រភេទពូជ ឬបច្ចេកទេសដាំដុះ ឬស្ថានភាពដុះលូតលាស់ របស់ដំណាំ។ ក្នុងពោតមួយដើមអាចមានចំនួនថ្នាំង ពី ៨ ដល់ ៣៨ ថ្នាំង ដោយយោងទៅតាមប្រភេទពូជ និង ស្ថានភាពដុះលូតលាស់របស់ដំណាំ ។ ជាមធ្យមក្នុងដើមពោតមួយដើមអាចមាន ២១ថ្នាំង ។ តាមថ្នាំងនិមួយៗ ចែកចេញជាចន្លោះថ្នាំង និង ថ្នាំងតែម្តង ដែលនៅថ្នាំងនិមួយជាប្រភពដុះចេញឬស, ស្លឹក, ផ្កា

និងពន្លកត្រួយ។

## ២.៤-ផ្កា

ផ្កាចែកចេញ ជាពីរយ៉ាងគឺផ្កាញី និងផ្កាឈ្មោល ស្ថិតនៅដាច់ដោយឡែកពីគ្នា ។ ផ្កាឈ្មោលស្ថិតនៅផ្នែកខាងចុងនៃដងដើម ហើយបែងចែកជាបីផ្នែកសំខាន់ៗគឺៈ ទងផ្កា, សំបកផ្កា និងកន្សោមលំអងផ្កា ឬ ថង់លំអង។ ផ្កាញីគឺជាស្មៀតពោត ដែលស្ថិតនៅចំកណ្ដាលនៃដងដើម, ផ្កាញីជាកញ្ចុំផ្កា ដែលនៅផ្តុំគ្នា ផ្កានិមួយៗមានថង់អូវ៉ុលមួយគូរ។ ជាទូទៅផ្កាញីចែកចេញជាពីរផ្នែកគឺ អូវ៉ុល និង អេស្ទីម"សក់ពោត"។



ផ្កាឈ្មោល



ផ្កាញី

### ២.៥-ផ្លែ



ផ្លែពោត ជាទូទៅស្ថិតនៅចំពាក់កណ្តាលនៃដងដើម ដែលមានកំពស់ពី៧០ ដល់ ២០០សង្ទីម៉ែត្រពីដី។ ជាលក្ខណៈវិទ្យាសាស្ត្រផ្លែពោតគឺជាគ្រាប់ពោត ហើយគ្រាប់ពោតទាំងនោះនៅផ្តុំគ្នាជុំវិញស្នូល និង គ្របដណ្តប់ដោយសំបកជាច្រើនស្រទាប់។ បណ្តុំគ្នានៃគ្រាប់ពោតទាំងនោះដែលយើងហៅថាផ្លែពោត។ ផ្លែពោតអាចមានប្រវែងប្រមាណពី ៨ ដល់ ៤២ ស.ម និងមានទំហំអាចប្រែប្រួលពី៣ទៅ៥ស.ម ។ ផ្លែពោតនិមួយៗ អាចមានគ្រាប់ពោតពី៣០០ទៅ១០០០គ្រាប់។

## ៣-ដំណាក់កាលលូតលាស់របស់ដំណាំពោត:

ដំណាក់កាលលូតលាស់របស់ដំណាំពោត ដោយយោងទៅតាមការដុះលូតលាស់ ផ្លាស់ប្តូររូបរាង និងការរីកចំរើនរបស់ដំណាំពោត គេបែងចែកដំណាក់កាលនៃការលូតលាស់របស់ដំណាំពោតជា៥ដំណាក់កាល:

### ៣.១-ចាប់ពីពេលដាំរហូតដល់ពន្លកស្លឹក

ដំណាក់កាលនេះ គិតចាប់តាំងពីពេលដែលយើងដាក់គ្រាប់ពោតដាំរហូតដល់ពេលដុះចេញបានស្លឹក ២ ទៅ ៣ ផុតពីដី។ រយៈពេលនេះគឺមានអាយុប្រមាណពី ៧ដល់១០ ថ្ងៃ បន្ទាប់

ពីថ្ងៃដាំ ។

**៣.២-ពន្លកស្លឹករហូតដល់ពេលចេញផ្កា:**

ក្នុងដំណាក់កាលនេះ គេអាចបែងចែកជាពីរដំណាក់កាល គឺការដុះលូតលាស់នៃចំនួនថ្នាំងនិងស្លឹក និងដំណាក់កាលមួយទៀត គឺការលូតលាស់នៃដងដើម ឬចន្លោះថ្នាំង និងការត្រៀមចេញផ្កា។ ក្នុងដំណាក់កាលទី១នេះ ដើមពោតនៅតូចទាប ដូច្នេះក្នុងចំការគ្មានស្មៅ និងមានទឹកគ្រប់គ្រាន់។ គិតពីថ្ងៃដាំ រហូតដល់ដំណាក់កាលនេះ គឺមានអាយុប្រមាណ៣០ថ្ងៃ។ ដំណាក់កាលទី២ គឺយើងសង្កេតឃើញដងដើមមានសន្ទុះលូតលាស់យ៉ាងលឿន និងដងដើមដុះលូតលាស់ពេញកំពស់និងរូបរាង។ ក្នុងដំណាក់កាលនេះ គឺទាមទារនូវទឹក និងជីជាតិគ្រប់គ្រាន់ ។ បើក្នុងចំការជួបប្រទះនឹងការរាំងស្ងួត ឬ គ្មានទឹកគ្រប់គ្រាន់ អាចបណ្តាលអោយការចេញផ្កាពុំបានល្អ ការដាក់គ្រាប់ពុំបានល្អ និងអាចបណ្តាលអោយថយចុះទិន្នផល។ គិតពីថ្ងៃដាំរហូតដល់ថ្ងៃចេញផ្កា គឺមានរយៈពេលប្រមាណពី៤០ ទៅ៧៥ថ្ងៃ ដោយយោងទៅតាមប្រភេទពូជ ។

**៣.៣-ពេលចេញផ្ការហូតដល់ពេលចេញផ្លែ:**

ដំណាំពោតចេញផ្កាជាទូទៅ នៅពេលពោតមានអាយុប្រមាណពី៤៥ ទៅ ៧៥ថ្ងៃ បន្ទាប់ពីថ្ងៃដាំ ឬ នៅពេលពោតមាន

បង្កាត់ចូលគ្នាហើយ។ រយៈពេលពីពេលបង្កាត់ រហូតដល់ពេលដាក់គ្រាប់ គឺប្រមាណជា ២១ថ្ងៃ និងរយៈពេលពីពេលដាក់គ្រាប់ដល់ពោតរឹង គឺប្រមាណ ជា ២៨ ទៅ ៣៥ថ្ងៃ។

### ៣.៥-ពេលទុំ

ពោតទុំ គឺគេសង្កេតឃើញដើមចាប់ផ្តើមប្រែពណ៌មកជាលឿង ស្លឹកចាប់ផ្តើមក្រៀមស្ងួត ហើយសំណើមក្នុងគ្រាប់មានត្រឹមតែ២៥%ប៉ុណ្ណោះ។ បើយើងប្រឡេះគ្រាប់ពោតនោះមើលយើងឃើញមានទងគ្រាប់ពណ៌ខ្មៅ ឬ ជាប់នឹងស្នូលមានពណ៌ខ្មៅ។ បើគិតចាប់ពីថ្ងៃដាំរហូតដល់ថ្ងៃទុំគឺប្រមាណ៩០ថ្ងៃ ទៅ ១៣០ថ្ងៃ ដោយយោងទៅតាមប្រភេទពូជ។

## ៤.តម្រូវការសារធាតុចិញ្ចឹមសម្រាប់ដំណាំពោត

ដំណាំពោត ក៏ដូចជាដំណាំផ្សេងទៀតដែរ ដើម្បីទទួលបានទិន្នផលខ្ពស់ ត្រូវធានាឲ្យបាននូវសារធាតុចិញ្ចឹមគ្រប់គ្រាន់សម្រាប់ការដុះលូតលាស់របស់ដំណាំនេះ។ សារធាតុអាសូត **N**, ផូស្វ័រ **P**, ប៉ូតាស្យូម **K** និងសារធាតុដទៃទៀត ត្រូវការចំបាច់បំផុតសម្រាប់ការចិញ្ចឹមដងដើម ។ ប្រសិនបើដីមានកំរិតPH KCL< 5 គប្បីបាចកំបោរសចំនួន៥០០គីឡូក្រាម/ហិកតា នៅពេលរាស់ដី។

សារធាតុអាសូត **N** ជាសារធាតុចាំបាច់បំផុតសម្រាប់ការ

បង្កើតសរីរាង្គដើម, ស្លឹក, ផ្កា, ផ្លែ និង ចូលរួមចំណែកក្នុងការបង្កើតជាតិប្រូតេអ៊ីន, អាមីដុង, វិតាមីន និង ការធ្វើរស្មីសំយោគ ។ សេចក្ដីត្រូវការសារធាតុអាសូតមានកំរិតប្រែប្រួលដោយយោងទៅតាមសភាពលូតលាស់របស់ដំណាំ ។ ដំណាំពោតត្រូវការសារធាតុអាសូត សម្រាប់មួយជីវិតរបស់ដំណាំពោតគឺប្រមាណ១៩០គក្រ/ហាត។

សារធាតុផូស្វ័រ **P** ជាសារធាតុមួយចាំបាច់សម្រាប់ដំណាំពោតផងដែរ គឺរួមចំណែកក្នុងការបង្កើត និងបំបែកកោសិកាថ្មី ហើយសារធាតុនេះរួមចំណែកក្នុងការបង្កើតត្រួយ, ស្លឹក, ឫស, ពន្លកផ្កា, ជាថាមពលក្នុងការបង្កើតផ្កាញី, ផ្កាឈ្មោល, ការបង្កាត់ និងបង្កើតគ្រាប់ពោត។

បរិមាណសរុប ដែលដំណាំពោតត្រូវការសារធាតុផូស្វ័រ គឺប្រមាណជា៣៩គក្រ/ហាត ។

សារធាតុប៉ូតាស្យូម(**K**) សារធាតុប៉ូតាស្យូមមានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតជាតិស្ករ អាមីដុង ប្រូតេអ៊ីន ការបង្កើតកោសិកាផ្សេងៗ និងរួមចំណែកក្នុងការសម្រួលកំរិតសីតុណ្ហភាព និងទឹកក្នុងសរីរាង្គនៃដងដើម។ ដើមពោតបានស្រូបយកសារធាតុប៉ូតាស្យូមយ៉ាងខ្លាំង នៅពេលដែលមានអាយុពី២៥ថ្ងៃ បន្ទាប់ពីថ្ងៃដាំរហូតដល់ពេលចាប់ផ្ដើមកកើតផ្លែ។

បរិមាណប៉ូតាស្យូម ដែលដំណាំពោតត្រូវការសម្រាប់មួយជីវិតនៃការលូតលាស់គឺប្រមាណជា១៩៦គក្រ/ហាត។ កាលដែលមានសារធាតុប៉ូតាស្យូមគ្រប់គ្រាន់ ក្នុងដើមធ្វើឲ្យដំណាំនេះធន់ទ្រាំ នឹងជម្ងឺ និងការបំផ្លាញនៃសត្វល្អិតផ្សេងៗ។

## ៥-តម្រូវការទឹកសម្រាប់ដំណាំពោត

ចំពោះដំណាំពោត កំរិតនៃបរិមាណទឹកដែលត្រូវការគឺប្រែប្រួលទៅតាមដំណាក់កាលលូតលាស់របស់ដំណាំ។ ពេលដំណាំពោតនៅតូច សេចក្តីត្រូវការទឹកតិចតួចល្មម គឺត្រូវការសំណើមក្នុងដីប្រមាណពី៣០ ទៅ ៥០% នៅដំណាក់កាលត្រៀមចេញផ្ការហូតដល់ការលូតលាស់ផ្លែ គឺពោតត្រូវការសំណើមក្នុងដីខ្ពស់ពី ៥០ ដល់ ៧០% ។ បើក្នុងដំណាក់កាលពោតនៅតូចមានទឹកច្រើនហួសហេតុពេក អាចបណ្តាលឲ្យកូនពោតខ្វះខ្យល់ក្នុងដីធ្វើឲ្យប៉ះពាល់ដល់ការលូតលាស់ ផ្ទុយទៅវិញបើពេលចេញផ្កាខ្វះទឹក គឺអាចបណ្តាលឲ្យថយចុះទិន្នផលយ៉ាងខ្លាំង។

## ៦-បច្ចេកទេសដាំដុះ និង ការថែទាំ

៦.១ រដូវកាលដាំដុះ: ពេលវេលា ឬរដូវកាលដាំដុះដំណាំពោតជាទូទៅគេអាចដាំបាន២រដូវក្នុងមួយឆ្នាំ:

- រដូវដើមឆ្នាំ និង រដូវចុងឆ្នាំ ឬ រដូវទឹកសម្រក
- រដូវកាលដាំដុះដំណាំពោតនៅប្រទេស កម្ពុជា

- រដូវដើមឆ្នាំ  ចាប់ពីខែមេសា-សីហា

- រដូវ សម្រក ចាប់ពីខែវិច្ឆិកា-កុម្ភៈ

៦.២-ការរៀបចំដី:

ដើម្បីធានានូវការដាំដុះដំណាំពោតនេះបានល្អ យើងត្រូវជ្រើសរើសដីដែលមានលក្ខណៈដូចតទៅៈ ដីដែលជ្រោះទឹកបានល្អ, ដីមិនហាប់, ដីដែលមានជីជាតិច្រើន, pHពី ៦ ទៅ ៧ ដីដែលគ្មានជាតិជូរ ឬ ប្រៃខ្លាំង និង ដីដែលគ្មានជាតិពុល។ នៅប្រទេសកម្ពុជាយើង ដីដែលសមស្រប សម្រាប់ដំណាំពោត គឺដី នៅតាមមាត់ទន្លេ ស្ទឹង, អូរ ព្រែក, ដីនៅតាមជើងភ្នំ ឬ នៅតំបន់ខ្ពង់រាប និង ដីក្រហម។

តួនាទី និង សារៈប្រយោជន៍នៃការរៀបចំដី គឺធ្វើយ៉ាងណាឲ្យដីមានសភាពម៉ត់ល្អ ដែលយើងអាចបង្កប់គ្រាប់ពោតចូលក្នុងដីបាន និង គ្រាប់ពោតស្ថិតក្នុងលទ្ធភាពមួយ ដែលអាចទទួលសំណើមបានគ្រប់គ្រាន់ និង អាចជៀសវាងបាននូវការបំផ្លាញរបស់សត្វផ្សេងៗ។ ម្យ៉ាងទៀតយើងអាចភ្ជួរបង្កប់នូវដើមពោតដែលបានប្រមូលផលរួចហើយ នៃរដូវកន្លងមក និងស្មៅរុក្ខជាតិផ្សេងៗ ឲ្យងាប់នៅក្នុងដី ហើយក្លាយទៅជាប្រភពនៃជីធម្មជាតិយ៉ាងល្អប្រសើរ។ សារៈប្រយោជន៍ផ្សេងទៀត គឺរក្សាសំណើមក្នុងដីបានយូរ, បង្កើនបន្ទុកខ្យល់ក្នុងដីបានគ្រប់គ្រាន់, ដើម្បី

ជំនួយដល់ចលនារបស់បាក់តេរីក្នុងការរំលាយជីធម្មជាតិ និង សារធាតុខនិជ, ដើម្បីបំផ្លាញចោល និងសម្លាប់សត្វល្អិតផ្សេងៗ ពងមេអំបៅ, ដង្កូវ ជម្ងឺផ្សេងៗ និង ស្មៅតាមរយៈការហាលដី នឹងដើម្បីបង្កលទ្ធភាពឲ្យឫសពោតដុះលូតលាស់បានល្អ។

➤ *ការភ្ជួររាស់ដីសម្រាប់ដំណាំពោត គឺយើងអនុវត្តដូចតទៅ:*

ភ្ជួរលើកទី១

- ត្រូវភ្ជួរក្នុងរយៈពេលពី១៥ថ្ងៃ ទៅ ៤០ថ្ងៃមុនថ្ងៃដាំ
- ភ្ជួរឲ្យបានជម្រៅ ពី ១៥ ទៅ ២៥ ស.ម
- ការភ្ជួរដី ត្រូវភ្ជួរនៅពេលសំណើមក្នុងដីមានប្រមាណ ៣០ ទៅ ៥០% ធ្វើយ៉ាងណាឲ្យដីបែកផុសល្អ។
- ការភ្ជួររាស់នៅរដូវប្រាំង (រដូវទឹកសម្រកតាមតំបន់មាត់ទន្លេ) បន្ទាប់ពីការភ្ជួររាស់ហើយ គឺត្រូវរាស់បំបែកដីដើម្បីឲ្យដីម៉ត់ល្អនិង ជៀសវាងការហួតទឹកពីក្នុងដី។

ភ្ជួរលើកទី២

ការភ្ជួរលើកទី២ គឺត្រូវអនុវត្តន៍ ១ ទៅ ៣ថ្ងៃ យ៉ាងយូរមុនថ្ងៃដាំ។ ការភ្ជួរលើកទី២នេះ គឺសំខាន់បំផុតត្រូវជ្រើសរើសពេលវេលាឲ្យបានសមស្រប ពិសេសពាក់ព័ន្ធនឹងសំណើមក្នុងដី គឺមានន័យថា ពេលដែលយើងភ្ជួរដីលើកទី២នេះ សំណើមក្នុងដី

ត្រូវគ្រប់គ្រាន់ល្អសម្រាប់ការដាំនឹងធានាឲ្យដំណាំដុះល្អ។ ជាទូទៅការភ្ជួរលើកទី២ គឺអនុវត្តបន្ទាប់ពីមានភ្លៀងធ្លាក់ជោគជាំហើយ។

-ការភ្ជួរលើកទី២ត្រូវភ្ជួរឲ្យបានជម្រៅពី២០ទៅ២៥សម។

-ការភ្ជួរលើកទី២ត្រូវភ្ជួរដីឲ្យបានម៉ត់ល្អ ជាទីបំផុតដើម្បីធានាដល់ការដុះលូតលាស់បានល្អ។

៦.៣-ការដាំដុះ និង ថែរទាំ

ក-ការជ្រើសរើសពូជ

-ពូជដែលផ្តល់ទិន្នផលខ្ពស់ (ពូជទំនើប,ពូជសុទ្ធល្អ,ពូជដែលសមស្របតាមតំបន់)

-ពូជដែលមានអាយុកាល លូតលាស់ សមស្រប និង លក្ខណ: ភូមិសាស្ត្រ និង អាកាសធាតុ

-គ្រាប់ពូជ ដែលថ្មីមិនទុកយូរឆ្នាំ

-គ្រាប់ពូជសុទ្ធ ដែលមានភាពសុទ្ធ លើសពី៩៨%

-គ្រាប់ពូជដែលមានកំរិតដំណុះលើសពី៨៥ ដល់ ១០០%

-គ្រាប់ពូជស្អាតគ្មានជម្ងឺ, សត្វល្អិតបំផ្លាញ និង បែក

-គ្រាប់ពូជស្ងួតល្អ ដែលមានសំណើមក្នុងគ្រាប់

ត្រឹម ១៣-១៤%

-បរិមាណគ្រាប់ពូជចន្លោះពី១២ទៅ១៧គីឡូក្រាម ក្នុង១ហិកតា

ខ-របៀបដាំដុះ

-ដាំដោយកាប់រណ្តៅដាំ ឬ បុកដាំតែម្តង

-ដាំ២-៣គ្រាប់ក្នុងមួយគុម្ព

-ដាំកណ្តាលរងដោយចន្លោះជួរ

-ចន្លោះជួរ៧៥ស.ម និងចន្លោះគុម្ព៣០-៤០ស.ម

-ចន្លោះជួរ៧៥ ស.ម និងចន្លោះគុម្ព៥០-៦០ស.ម

-បុកដាំឬកប់គ្រាប់ពូជអាស្រ័យរដូវកាលដាំដុះ

-នៅរដូវវស្សា៖ ជម្រៅ ៣-៥ ស.ម

-នៅរដូវប្រាំង៖ ជម្រៅ៥-៨ស.ម ( ដាំស្រោចទឹក )



៦.៤-ការដាក់ជី

ជាទូទៅការដាំពោតត្រូវធ្វើការដាក់ជី ឲ្យបានត្រឹមត្រូវ ដើម្បីធានាក្នុងការផ្តល់សារធាតុចិញ្ចឹមគ្រប់គ្រាន់ដល់ដំណាំ និង រក្សាគុណភាពដីឲ្យបានល្អ ។ បរិមាណនៃការដាក់ជីសម្រាប់ ដំណាំពោតអាចប្រែប្រួល ដោយយោងទៅតាមសភាពជីជាតិ ដែលមានក្នុងដី។



ជីធម្មជាតិ៖ ការដាក់ជីធម្មជាតិ គឺមានសារៈសំខាន់បំផុត ដែលធ្វើឲ្យគុណភាពដីឲ្យ កាន់តែល្អប្រសើរថែមទៀត និង ផ្តល់ជីជាតិបានល្អក្នុងរយៈពេលមួយយូរអង្វែង។ ក្នុងករណីយនេះយើងប្រើជីលាមកសត្វ, ជីកំប៉ុស្ត និង កំទេចកំទីសំរាមផ្សេងៗក្នុងបរិមាណប្រមាណ ១០-២០ តោន/ហិកតា។

-ជីគីមី៖ ចំពោះដីដែលមានលក្ខណៈធម្មតាគឺយើង

➤ អាចដាក់ជីអាសូត (**N**) ២១៧គក្រ/ហ.ត

➤អាចដាក់ជីផូស្វរ័ (**P**) ១៥៦ គក្រ/ហ.ត

➤និងអាចដាក់ជីប៉ូតាស់(**K**)១៥៨ គក្រ/ហ.ត។

-ចំពោះដីដែលមានលក្ខណៈខ្សោះជីជាតិគឺយើង

➤អាចដាក់ជីអាសូត (**N**) ២៦៩គក្រ/ហ.ត

➤អាចដាក់ជីផូស្វរ័ (**P**) ២៩០គក្រ/ហ.ត

➤និងអាចដាក់ជីប៉ូតាស់(**K**) ២០០គក្រ/ហ.ត។

ការប្រើប្រាស់ជីត្រូវចែកជាបីដំណាក់កាលគឺ: ដាក់ទ្រាប់បាតៈអ៊ុយរ៉េ៥០%, ផូស្វ័រ និងប៉ូតាស្យូម១០០% ចំណែកអ៊ុយរ៉េនៅសល់៥០%ប្រើសម្រាប់ដាក់បំប៉នពីរលើកទៀត គឺលើកទី១: ២៥% ក្រោយដាំ២០-២៥ថ្ងៃ និងបំប៉នលើកទី២:២៥%ក្រោយដាំ៤០-៤៥ថ្ងៃ។

ការដាក់ជីបំប៉នត្រូវដាក់ឲ្យឆ្ងាយពីគល់ពី ១០-១៥ ស.ម រួចពូនដីលុបឲ្យជិត ដើម្បីទប់គល់ពោតផង និងការពារជីមិនឲ្យបាត់បង់តាមរយៈការហើរទៅក្នុងបរិយាកាស និងការហូរច្រោះដោយសារទឹក។

របៀបនៃការប្រើប្រាស់ជីលើពូជពោតបង្កាត់:

-មុនពេលដាំដាក់ជីទ្រាប់បាតNPK 20-20-15+TE ចំនួន ១៥០គីឡូក្រាមឬ NPK 16-16-8-13S ២០០គីឡូក្រាម/ហិកតា។

-ដាក់ជីបំប៉នពេលដំណាំពោតមាន ៦-៨ស្លឹក ប្រើNPK 16-8-16 ឬ 15-15-15 ចំនួន២០០គីឡូក្រាម/ហិកតា។

-ដាក់ជីបំប៉នពេលដំណាំពោតមាន១០-១២ស្លឹក (មុនពេលពោតចេញផ្កា) ប្រើNPK 16-8-16 ឬ 15-15-15 ចំនួន១៥០គីឡូក្រាម/ហិកតា។

## ៧-ការកម្ចាត់ស្មៅ

ការសំអាតស្មៅ គឺជាការងារចាំបាច់បំផុតក្នុងការដាំដុះដំណាំពោតដើម្បីធានាបាននូវទិន្នផលខ្ពស់ លុះត្រាតែយើងធានាយ៉ាងណាគឺក្នុងការសម្អាតស្មៅ ក្នុងចំការឲ្យបានល្អជាដាច់ខាតរហូតដល់ពេលពោតចេញផ្ការួច។ បើក្នុងដំណាក់កាលមុនពេលចេញផ្កា ដំណាំពោតត្រូវស្មៅបំផ្លាញ ឬបោកអាចបណ្ដាលឲ្យថយទិន្នផលយ៉ាងខ្លាំង។ បន្ទាប់ពីពោតចេញផ្ការួច ឬ ក្នុងដំណាក់កាលលូតលាស់ផ្លែ អាចមានស្មៅដុះខ្លះបាន។

ការងារសម្អាតស្មៅ គឺយើងអនុវត្តន៍ដូចតទៅ:

-ពេលភ្ជួររាស់ហាលដីសម្លាប់ស្មៅ

-ជំរះស្មៅលើកទី១ ពេលពោតអាយុបានប្រមាណ១៥ថ្ងៃបន្ទាប់ពីដាំ

-ជំរះលើកទី២ ពូនគល់អាយុបានប្រមាណ៣០ថ្ងៃបន្ទាប់ពីថ្ងៃដាំ

-និងជំរះស្មៅលើកទី៣ ក្នុងករណីចាំបាច់ពេលពោតមានអាយុបានពី៥០ ទៅ ៦០ថ្ងៃ។

# ៨-ជម្ងឺ និងសត្វល្អិតចង្រៃ

## ៨.១ ជម្ងឺ

### ៨.១.១ ជម្ងឺរលួយគ្រាប់ពោត(**Seed Rot**)



ជម្ងឺនេះបង្កឡើងដោយផ្សិត និង បាក់តេរីPythium, Fusarium, diplodia,Rhizoctonia, Penicillium.spp។ រោគសញ្ញានៃជម្ងឺនេះ គឺវារលួយអំប្រិយ៉ុង ហើយងាប់នៅមុនពេលវាដុះពន្លកមកម្លេះ។

វិធានការការពារ និងកំចាត់៖

-ទុកដាក់គ្រាប់ពូជឱ្យបានត្រឹមត្រូវ

-ហាលគ្រាប់ពូជមុននឹងយកទៅដាំ

-ត្រាំគ្រាប់ពូជនឹងទឹកក្ដៅអ៊ុនៗ មុននឹងយកទៅដាំ

-ភ្ជួរហាលដីឱ្យបានស្ងួតល្អ

### ៨.១.២ជម្ងឺស្លោកស្លឹកលើកូនពោត(**Seedling Blights**)

ជម្ងឺនេះ កើតឡើងនៅលើកូនពោតទើបនឹងដុះពន្លក ។ រោគសញ្ញានៃជម្ងឺនេះ បណ្ដាលឱ្យកូនពោតស្លោកស្រពោនងាប់តែម្ដង។ ចំពោះគ្រាប់ពោតដែលមានរោគសញ្ញានេះមានពណ៌ស ឬ ផ្កាឈូកមានផ្សិតដុះជុំវិញបណ្ដាលឱ្យគ្រាប់រលួយ ។

ចំពោះគ្រាប់ពូជឬ ដីដែលមានពពួកផ្សិត គឺបណ្តាលឱ្យកូនពោតកើតជម្ងឺblightsនេះ ។ កុំច្រឡំជម្ងឺនេះទៅនឹងស្នាមបំផ្លាញរបស់សត្វល្អិត ។ ជាញឹកញាប់វាកើតឡើងនៅពេលដែលមានការដាំដុះដំណាំពោតឃើតមិនទាន់ពេលវេលា ។ ចំពោះដីដែលជាំទឹកខ្លាំង ឬដីដែលស្ងួតខ្លាំងវាអាចកាត់បន្ថយជម្ងឺនេះ។ ជម្ងឺBlights នេះ ច្រើនកើតឡើងយ៉ាងឆាប់រហ័សទៅលើកូនពោត ធ្វើឱ្យស្លឹកឡើងស្លោកៗ និងអុចសៗហើយរីករាលដាលរហូតដល់ដំណាក់កាលលូតលាស់ដើមស្លឹក ។ ជាទូទៅជម្ងឺនេះច្រើនកើតនៅក្នុងខែមេសា និងដើមខែឧសភា ។

វិធានការពារ និងកំចាត់ជម្ងឺនេះមានដូចជា:

-ព្យាបាលគ្រាប់ពូជ

-កែលំអប្រព័ន្ធបង្ហូរទឹក

-ដកដើមដែលមានជម្ងឺដុតចោល



៨.១.៣ ជម្ងឺរលួយគល់



ជម្ងឺរលួយគល់ ឬស្វិតគល់ បង្កឡើងដោយមេរោគផ្សិតជាច្រើនប្រភេទ លក្ខខណ្ឌកើតជម្ងឺនេះគឺបណ្ដាលមកពីដីពុំបានភ្ជួរ ឬសម្លាប់មេរោគក្នុងដី និងគ្រាប់ពូជឲ្យបានត្រឹមត្រូវ ។ ម្យ៉ាងទៀតទឹកយកមកស្រោចស្រពមានស្ព័រផ្សិត និងសីតុណ្ហភាពដីប្រែប្រួលសំណើមខ្ពស់ ។ រោគសញ្ញាជម្ងឺនេះគឺប្រែពណ៌ពីបៃតងទៅបៃតងស្រអាប់ ហើយស្លឹកក្ងទីលេដុងស្វិតជ្រុះ វាបង្កឡើងដោយពពួក Rythium Specis លើកូនដំណាំខ្ចីៗ ទើបនឹងដុះ។ ចំពោះជម្ងឺដែលបង្កឡើងដោយ Rhyzoctonia Solanie រោគសញ្ញាប្រហែលគ្នានឹង Rythiumដែរ ប៉ុន្តែលេចចេញនូវពណ៌ក្រហមចាស់ ឬពណ៌ត្នោតនៅលើស្នាមរបួស ធ្វើឱ្យកូនដំណាំខ្ចីទន់ជ្រាយ ហើយស្វិតគល់កូនដំណាំអាចងាប់បាន ។ ជម្ងឺដែលបង្កឡើងដោយ Fusarium egriseti ធ្វើឱ្យស្ងួតក្រហមត្នោតផ្នែកក្បាលពន្លក និងឫសក្នុងដីដែលហៅថា Hypocotyl បណ្ដាលឱ្យទន់ ព្រោះមេរោគនេះតែងតែមានវត្តមានប្រចាំការមុន និង

ក្រោយដុះពន្លក ។ ជម្ងឺដែលបង្កឡើងដោយផ្សិតទាំង៣នេះ គឺបំផ្លាញតាំងពីដុះពន្លកដល់ពោតអាយុ២អាទិត្យ ដែលធ្វើឱ្យពោតងាប់ ប៉ុន្តែចាប់ពី២អាទិត្យឡើងទៅ ដំណាំមិនងាប់ដោយសារវាឡើយ។

៨.១.៩ជម្ងឺអុចស្លឹកពោត(ភ្នែកចាប)



ជម្ងឺអុចស្លឹកពោតជាប្រភេទជម្ងឺមួយ ដែលគេសង្កេតឃើញកើតមាននៅលើដំណាំពោត ដែលមានសញ្ញានិងរោគសញ្ញាស្នាមជារង្វង់មានចំណុចពណ៌ត្នោតចាស់នៅចំកណ្ដាល និងមានស្នាមពណ៌លឿងក្រមៅព័ទ្ធជុំវិញ ។ ជម្ងឺនេះកើតមានពាសពេញផ្ទៃស្លឹក ដែលបង្កឡើងដោយពពួកផ្សិត។ ការរាលដាលនៃជម្ងឺនេះពីដើមមួយទៅដើមមួយ ឬពីចំការមួយទៅចំការមួយតាមរយៈការស្រោចស្រព ខ្យល់ ឧបករណ៍សំភារៈដឹកជញ្ជូន និងការអនុវត្តន៍ផ្សេងៗរបស់មនុស្ស។ កត្តាដែលនាំឲ្យកើតជម្ងឺនេះឡើងគឺដោយសារបរិយាកាសសមស្រប កំដៅខ្លាំង សំណើមបរិយាកាសខ្ពស់។

វិធានការការពារ និងកំចាត់មានដូចជា

-ការដាំដុះឲ្យសមស្របតាមរដូវកាល

-រៀបចំដីឲ្យបានស្អាត

-ប្រមូលកាកសំណល់ដែលមានជំងឺដុតចោលសម្អាតគ្រាប់ពូជឲ្យបានស្អាតមុនពេលដាំដុះ

៨.១.៥ ជម្ងឺធ្យូងខ្មៅ (**Ustilago**)



ជម្ងឺធ្យូងខ្មៅ ជាប្រភេទជម្ងឺមួយដែលគេសង្កេតឃើញ កើតមាននៅលើដំណាំពោត ដែលមានសញ្ញានិងរោគសញ្ញាស្នាមនៅលើស្លឹកពណ៌ក្រមៅ មានជារង្វង់ពណ៌លឿង វាកើតមាននៅសីតុណ្ហភាពពី២០-៣០អង្សាសេ និង មានសំណើមខ្ពស់។ វាបំផ្លាញនៅលើសរីរាង្គផ្នែកខាងលើនៃដី ជាពិសេសផ្នែកដែលមានជាលិកាខ្ចីៗ គឺមានសកម្មភាពលូតលាស់ខ្លាំង ជម្ងឺនេះបង្កឡើងដោយផ្សិតឈ្មោះKabatiellazeae ដោយបង្កើតជាដុំពកៗនៅលើស្លឹក ដើម ផ្កា ផ្លែ ។ នៅដំណាក់កាលដំបូងមានពណ៌បៃតង ឬ ទឹកប្រាក់បន្ទាប់មកក្លាយជាពណ៌ត្នោតខ្មៅ ដូច

ធ្យូង បើកើតនៅលើដើមវាធ្វើឱ្យដើមតៀទាប តែដើមអាចរស់ធម្មតា។ កត្តាដែលនាំឱ្យកកើតជម្ងឺនេះឡើង ដោយសារបរិយាកាសសមស្រប កំដៅខ្លាំង សំណើមខ្ពស់ ។ ហេតុនេះដើម្បីការពារជម្ងឺនេះ ត្រូវមានវិធានការការពារ និងកំចាត់ គឺការដាំដុះឲ្យបានសមស្របទៅតាមរដូវកាល រៀបចំដីចំការឲ្យបានស្អាតប្រមូលសំណាកពោតកើតជម្ងឺចេញពីចំការ ឬ ដុតសំណាកពោតកើតជម្ងឺចោល ពិសេសមុនពេលដាំយើងត្រូវជ្រើសរើសគ្រាប់ពូជដែលល្អគ្មានជម្ងឺ ។

ជ.១.៦ណេម៉ាតូថ **(Nematode)**

ជាច្រើនប្រភេទជាពិសេសលើដំណាំពោត ។ ណេម៉ាតូថជាភ្នាក់ងារបង្ករោគមានជីវិតម៉្យាង ដូចជាពពួកសត្វល្អិត ដែលវាអាចជ្រៀតចូលតាមប្រហោងនៃប្រព័ន្ធឫសរុក្ខជាតិ ។ សញ្ញា និងរោគសញ្ញានៃជម្ងឺនេះ គឺស្លឹកពោតពណ៌ស្វាយ ឬក្រហម ឬសពកៗរឆេញរឆ្ងួញ ដើមតឿ ក្រិន បង្អាក់ការលូតលាស់ ។ ការឆ្លងរាលដាលជម្ងឺនេះតាមរយៈទឹក និងដី ។ កត្តាដែលនាំឱ្យកើតជម្ងឺនេះ ដោយសារបរិយាកាសសមស្រប មានចំណីអាហារគ្រប់គ្រាន់ ។

វិធានការការពារ និង កំចាត់ជម្ងឺនេះមានដូចជា:

-ជ្រើសរើសពូជធន់

-រៀបចំដីឱ្យបានស្អាត

-ផ្លាស់ប្តូរមុខដំណាំ

-ប្រើជីលាមកសត្វស្ងួតល្អ ប្រមូលកាកសំណល់បំផ្លាញចោល។

## ៨.១.៧ ជម្ងឺច្រេះស្លឹក(**Rust spot of Gray leaf spot**)



បង្កជម្ងឺដោយមេរោគឈ្មោះPucciniasorghi លក្ខខណ្ឌដែលបង្កឱ្យមានជម្ងឺងាយស្រួលកកើត គឺនៅរដូវក្តៅហើយសើមស្ព័រនៃផ្សិតព្រោះវាអាចរីករាលដាលយ៉ាងលឿន ដោយសារដំណក់ទឹក។ វាច្រើនតែកើតឡើង នៅដំណាក់កាលបន្តពូជ គេច្រើនពិនិត្យឃើញស្លឹកពោតមានចំណុចតូចៗពណ៌លឿង ក្រោយមកចំណុចនេះពង្រីកខ្លួនកាន់តែធំឡើងៗ ហើយប្តូរពណ៌ទៅជាពណ៌ប្រផេះ។ នៅពេលដែលមានការបំផ្លាញខ្លាំង ធ្វើឲ្យស្លឹកពោតប្រែពណ៌ទៅជាស្រអាប់ និងស្ងួតចុងស្លឹក។

### ៨.១.៨ ជម្ងឺពុកដើម(**Antracnose)**

នៅដំណាក់កាលពោតចាប់ផ្តើមចេញផ្កាឈ្មោលដំបូង យើងសង្កេតឃើញមានជម្ងឺពុកដើមកើតមាន ដើម និងស្រទបស្លឹកជាប់នឹងដើម មានស្នាមរលាកជាំៗ ក្រោយមកស្ងួត ។ រីឯចន្លោះថ្នាំងមានពណ៌ព្រឿងៗ ស្លឹកស្ងួតជាបណ្តើរៗ ។ ពោតដែលកើតមានជម្ងឺនេះ ផ្លែទុំមិនពេញលេញដោយសារដើមវាពុកនៅពេលមានភ្លៀង ខ្យល់ វាដួលរលំភ្លាម ។ ជម្ងឺនេះកើតឡើងដោយផ្សិតបំផ្លាញដំណាំ ពេលមានអាកាសធាតុក្តៅហើយសើម ជាពិសេសបង្កមកពីកាកសំណល់ដែលនៅសល់ពីរដូវមុនៗ ។ ដើម្បីទប់ទល់នឹងជម្ងឺនេះ ត្រូវដុតកាកសំណល់ចោលឲ្យអស់ គ្រប់គ្រងសំណើមឲ្យបានល្អ ការដាំដុះត្រូវគិតពីចន្លោះគុម្ព និងជួរ ធ្វើយ៉ាងណាឲ្យមានពន្លឺថ្ងៃចាំងចូលគ្រប់គ្រាន់ ។ មុននឹងដាំត្រូវលាយគ្រាប់ជាមួយថ្នាំ Mancozeb កំរិត២ភាគរយ ហើយពេលលេចចេញរោគសញ្ញានៃជម្ងឺនេះ ត្រូវបាញ់ថ្នាំផ្សិត៧ថ្ងៃម្តង។



៨.១.៩ ជម្ងឺរលួយធ្យូង( **Macrophomina Phaseole)**



ជម្ងឺរលួយធ្យូង ជាជម្ងឺមួយប្រភេទ ដែលបង្កឡើងដោយភ្នាក់ងារចំលង ឈ្មោះ **(Selerotia)** សេលេរ៉ូរីយ៉ា ។ មានជម្ងឺផ្សិតជាច្រើនប្រភេទផ្សេងៗទៀតកើតមាននៅក្នុងតំបន់អាស៊ីដូចជា ជម្ងឺផ្សិតទង សំបកនៃផ្លែ ជម្ងឺផ្សិតខ្មៅដូចធ្យូងដុំៗ ជាពិសេសនៅលើគ្រាប់ ។ ប៉ុន្តែជម្ងឺទាំងនេះ មិនបង្កឱ្យមានការបាត់បង់ទិន្នផលពោតធ្ងន់ធ្ងរទេ ។ នៅប្រទេសកម្ពុជាយើង ជម្ងឺរលួយធ្យូងច្រើនកើតនៅពេលគ្រោះរាំងស្ងួត អាកាសធាតុក្តៅខ្លាំង ផ្សិតវាអាចរស់នៅបានច្រើនខែ ក្នុងកាកសំណល់ពោត និងក្នុងដី។

៨.១.១០ ជម្ងឺស្រពោនបណ្តាលមកពីផ្សិត **(Fusarium Wilt)**



នៅប្រទេសកម្ពុជាយើង នៅរដូវវស្សា ពេលដំណាំពោតចាប់ផ្តើមបន្តពូជ យើងសង្កេតឃើញមានជម្ងឺស្រពោនស្លឹក

និងគល់កើតមានឡើង ។ ជម្ងឺនេះដំបូងវាធ្វើឱ្យដំណាំជួបការលំបាកក្នុងការស្រូបយកជាតិទឹក បន្ទាប់មកធ្វើឱ្យឫសចាប់ផ្តើមពុកផុយរលួយ ។ ទន្ទឹមនឹងនោះគេសង្កេតឃើញមានស្នាមរបួសជាំ នៅលើដើមពោត ធ្វើឱ្យការលូតលាស់ស្លឹកថយចុះ និងប្រែពណ៌ពីបៃតងទៅជាលឿងព្រឿងៗ ក្រោយមកស្រពោនស្វិត ។ ជម្ងឺនេះ បង្កឡើងដោយផ្សិតពេលអាកាសធាតុស្ងួត ស្ព័រវាហើរទៅប៉ះដើមដទៃ ហើយក៏ជ្រកទៅលើដើមនោះ ។ ក្នុងពេលនោះដែរ បើមានសំណើមគ្រប់គ្រាន់ វាក៏ចាប់ផ្តើមចូលទៅក្នុងឫស ។ ដើម្បីទប់ទល់នឹងជម្ងឺនេះត្រូវដាំដុះឱ្យមានចន្លោះគុម្ព និងជួរសមស្រប ដែលអាចពន្លឺថ្ងៃចាំងចូលបានល្អ




-សំអាតស្មៅ

-ដកដើមដែលកើតជម្ងឺចោល

-មុនពេលដាំដុះត្រូវប្រលាក់គ្រាប់ជាមួយថ្នាំផ្សិត (Mancozeb) ក្នុងកំរិត២ភាគរយ ហើយពេលឃើញមានលេចចេញរោគសញ្ញា នៃជម្ងឺនេះត្រូវបាញ់ថ្នាំផ្សិតការពារ ក្នុងចន្លោះ៧ថ្ងៃបាញ់ម្តង។

### ៨.១.១១ ជម្ងឺអុចត្នោត



ជម្ងឺអុចត្នោត ជាជម្ងឺមួយប្រភេទដែលបង្កឡើងដោយផ្សិត។ មានជម្ងឺផ្សិតជាច្រើនប្រភេទផ្សេងទៀត កើតមាននៅក្នុងតំបន់អាស៊ី ដូចជាជម្ងឺប្លាស ធ្វើឱ្យដើមពោតខ្ពស់ខុសពីធម្មតា (ពោតខ្វើយ) រលាកស្រទបស្លឹក រលួយស្រទបស្លឹក រលួយដើម រលួយឫស នឹងជម្ងឺផ្ទុះគ្រាប់ជាដើម ។ ជម្ងឺនេះមិនបង្កឲ្យបាត់បង់ទិន្នផលពោតទេ ។ នៅប្រទេសកម្ពុជាយើង ជំងឺអុចត្នោតកើតមាននៅលើដីស្ងួត ហើយខ្វះសារធាតុអាសូត (N) ។



### ៨.១.១២ ជម្ងឺរលួយផ្លែ និងដើម (**Gibberella Ear and Stalk Rot**)



ជម្ងឺរលួយផ្លែនេះ ជាញឹកញាប់គេកត់សម្គាល់ឃើញមានផ្សិតដុះ ដែលចាប់ផ្តើមពីផ្នែកខាងចុងនៃត្រចៀកស្លឹក ។ ចំពោះជម្ងឺរលួយដើមពោត ជាញឹកញាប់គេកត់សំគាល់ឃើញមុនដំបូងដើមមានសុខភាពល្អ បន្ទាប់មកវាប្រែក្លាយទៅជាស្លោត ហើយសរសៃទន់ធ្វើឱ្យការលូតលាស់មានសភាពយឺតយ៉ាវ ។ ជម្ងឺរលួយផ្លែ និង ដើមនេះវាបានកកើតឡើងនៅគ្រប់ទីកន្លែងនៃសហរដ្ឋអាមេរិច។ ជាធម្មតាជម្ងឺនេះកើតឡើងក្នុង សីតុណ្ហភាពក្រោម៧២°F អង្សាហ្វារិនហៃប្រហែល (៣៥ អង្សាសេ)។ នៅពេលមានភ្លៀងធ្លាក់ញឹកញាប់រយៈពេល២សប្តាហ៍ គឺវាងាយនឹងកើតជម្ងឺរលួយត្រចៀកពោតនេះណាស់។ ចំពោះរដូវវស្សា គឺមានការរាំងស្ងួតមួយរយៈក្នុងខែ៦-៧ ជម្ងឺមិនសូវជាមានបញ្ហាទេ។ នៅក្នុងខែ សីហា និង កញ្ញា គឺវាអំណោយផលក្នុងការកើតជម្ងឺGibberellaនេះ ដែលបណ្តាលឲ្យរលួយដើមពោតបានដោយងាយ ។ វិធានការ

ការពារ និងកម្ចាត់មានដូចជា




ប្រើពូជបង្កាត់ដែលធន់

-ដាំដំណាំបង្វិល

-ប្រើប្រាស់ជីឲ្យមានគុណភាព

-សម្អាតចំការ

-កម្ចាត់សត្វល្អិត

៨.១.១៣ ជម្ងឺផ្សិតរលួយគ្រាប់(**Fusarium Kernel Rot**)



ជម្ងឺផ្សិតរលួយគ្រាប់នេះ ធ្វើឲ្យសំបកផ្លែរបស់វា ប្រែពណ៌ទៅជាពណ៌ប្រផេះ ហើយគ្រាប់វាខាងក្នុងដាច់ៗពីគ្នា ហើយចាប់ផ្តើមស្អៀតបន្តិចម្តងៗ រហូតដល់ផ្នែកទាំងមូលនៃផ្លែតែម្តង ។ ជម្ងឺរលួយគ្រាប់បណ្តាលមកពីពពួកផ្សិតហ្វុយសារីយ៉ូម ហើយវាកកើតឡើងនៅគ្រប់ទីកន្លែង។ វាច្រើនកើត នៅពេលអាកាសធាតុក្តៅឬត្រជាក់វាបង្កលក្ខណៈងាយស្រួលដល់ពពួកសត្វល្អិតដែលវាស៊ីបំផ្លាញគ្រាប់ និងធ្វើឲ្យសក់ពោតជ្រុះ។ ម៉្យាងទៀតវានឹងវិវត្តន៍នៃជម្ងឺ Fusarium kernel បានយ៉ាងឆាប់រហ័ស។ ជម្ងឺផ្សិតនេះអាច

បណ្ដាលឲ្យរលួយ គ្រាប់ ហើយអាចពុលដល់គ្រាប់ដែលយើងស្ដុកទុកទៀតផង។ វិធានការការពារនិងកំចាត់:

-ប្រើពូជបង្កាត់ដែលធន់

-ដាំដំណាំបង្វិល

-សំអាតចំការ

### ៨.១.១៤ ជម្ងឺតុងគ្រោ



ជម្ងឺតុងគ្រោ គឺជាជម្ងឺម៉្យាងដែលបង្កឡើងដោយវីរុស។ មានជម្ងឺវីរុសជាច្រើនប្រភេទដែលកើតឡើងក្នុងតំបន់អាស៊ី ដូចជាជម្ងឺតឿលឿង តឿរួញស្លឹក តឿស្មៅ និងតឿស្លឹកសជាដើម។ ជម្ងឺនេះបំផ្លាញដំណាំពោតធ្ងន់ធ្ងរ ជាពិសេសក្នុងតំបន់ដែលមានការរាំងស្ងួតអូសបន្លាយពេលយូរក្នុងបណ្ដាប្រទេសមួយចំនួនក្នុងតំបន់អាស៊ី ។ ជម្ងឺនេះមិនបង្កការរាតត្បាតធ្ងន់ធ្ងរនៅប្រទេសកម្ពុជាទេ ។ រោគសញ្ញានៃជម្ងឺនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងស្រូវខ្វះអាសូតដែរ ។ ជម្ងឺតុងគ្រោច្រើនកើតនៅលើស្លឹកខ្ចីចំណែកជម្ងឺខ្វះអាសូត ច្រើនកើតនៅលើស្លឹកចាស់ៗមុន។

### ៨.១.១៥ ជម្ងឺតឿក្រិន( Maize dwarf mosaic Virus)



វាបង្កឡើងដោយភ្នាក់ងារចម្លងជម្ងឺជាពិសេសពពួកចៃ មមាច និងទ្រីប ។ ការលេចចេញជាសញ្ញានេះច្រើននៅក្នុងដំណាក់កាល មុនពេលចេញផ្កាវាធ្វើឲ្យដើមក្រិន ហើយតឿលែងមានការលូតលាស់ទៅមុខទៀត ។ ជម្ងឺនេះវាបណ្ដាលឲ្យពោតមិនអាចចេញផ្កាបាន តែវាមិនបណ្ដាលឲ្យដើមពោតងាប់ភ្លាមៗនោះឡើយ។ វាចម្លងជម្ងឺបានយ៉ាងរហ័សដោយសារចៃម៉្យាងឈ្មោះ Green peach Aphid។ ជម្ងឺវីរុសគឺជាប្រភេទ ជម្ងឺដែលពុំមានថ្នាំសម្រាប់កំចាត់ឡើយ ។ ដូច្នេះវិធានការការពារជាការប្រសើរដូចជា៖

-ការជ្រើសរើសពូជសុទ្ធ ដែលគ្មានជំងឺពីមេបា

-ប្រើពូជធន់

-គ្រប់គ្រងស្មៅឲ្យបានត្រឹមត្រូវ

-ការដាំដុះឲ្យទាន់ពេលវេលា ដែលវាគ្មានទំនាក់ទំនងជាមួយនឹងការកកើតនៃពួកសត្វល្អិត

-ផ្លាស់ប្ដូរមុខដំណាំ

-ទាំងដកដើមណា ដែលលេញចេញនូវសញ្ញាវីរុស ហើយដុតចោល។

### ៨.១.១៦ ជម្ងឺតៀលឿង(Mosaic Virus)




បង្កឡើងដោយមេរោគឈ្មោះ Peregrinus maidis ដែលការបំផ្លាញនេះ ច្រើនតែនៅដើមរដូវភ្លៀង ដែលវាអាចចំលងជំងឺដោយមមាចជញ្ជក់ស្លឹក Leaf hoper ជាពិសេសនៅក្នុងដំណាក់កាលបន្តពូជ ដែលវាបណ្តាល អោយដើមមានសភាពតឿ និងស្ងួតស្លឹក តែពេលនេះពោតអាចចេញផ្កាឈ្មោលបាន ប៉ុន្តែវាមិនអាចចេញផ្កាញីបានទេ។ ជម្ងឺនេះគ្មានថ្នាំសំរាប់កំចាត់ទេ តែមានវិធីការពារជាច្រើនដូចជា:

-ការជ្រើសរើសពូជសុទ្ធ ដែលគ្មានជម្ងឺពីមេបា

-ប្រើពូជធន់

-គ្រប់គ្រង់ស្មៅអោយបានត្រឹមត្រូវ

-ការដាំដុះឲ្យទាន់ពេលវេលា ដែលវាគ្មានទំនាក់ទំនងជាមួយនឹងការកកើតនៃពួកមមាច

-ផ្លាស់ប្តូរមុខដំណាំ

-ដកដើមណា ដែលលេញចេញនូវសញ្ញាវីរុសហើយ
ដុតចោល។

### ៨.១.១៦ ជម្ងឺរីងស្លឹក(Sugarcane Mosaic Virus)



ជម្ងឺនេះបង្កឡើងដោយមេរោគឈ្មោះCicadullina spp។ ជម្ងឺនេះកើតឡើងស្ទើរតែពេញមួយឆ្នាំ ប៉ុន្តែនៅរដូវប្រាំងមានការបំផ្លាញច្រើនជាង នៅរដូវវស្សា ដែលជម្ងឺនេះចម្លងដោយ Thrip និង Hopper សំខាន់ជាងគេ។ វាធ្វើឲ្យស្លឹកពោតមានពណ៌បៃតងក្រមៅក្រាស់ ហើយរីងដូចជាស្លឹកអំពៅ ឈរត្រង់ទ្រនុងស្លឹកធំៗ ហើយវាងាយបាក់ណាស់ វាច្រើនបំផ្លាញនៅដំណាក់កាលបង្កើនសរីរាង្គបន្តពូជ។ ជម្ងឺនេះគ្មានថ្នាំសម្រាប់កំចាត់ទេ តែមានវិធីការពារជាច្រើនដូចជា:

-ការជ្រើសរើសពូជសុទ្ធដែលគ្មានជម្ងឺពីមេបា

-ប្រើពូជធន់

-គ្រប់គ្រង់ស្មៅអោយបានត្រឹមត្រូវ

-ការដាំដុះអោយទាន់ពេលវេលាដែលវាគ្មានទំនាក់

ទំនងជាមួយនឹងការកកើតនៃពួកមមាច និង ទ្រីប

-ផ្លាស់ប្តូរមុខដំណាំ

-ដកដើមណាដែលលេញចេញនូវសញ្ញាជម្ងឺវីរុសដុតចោល។

## ៨.២ សត្វល្អិតចង្រៃ

### ៨.២.១ដង្កូវរុយចោះគ្រាប់ពោត(Seed Corn Maggot)



ដង្កូវរុយចោះគ្រាប់នេះ វាស៊ីបំផ្លាញគ្រាប់ពោត ដែលដុះពន្លក ធ្វើឱ្យមានការខូចខាតទាំងស្រុង ។ សត្វល្អិតនេះមានពណ៌លឿងភ្លាវ ហើយដង្កូវរុយនេះគ្មានជើងទេ ។ ស្នាមបំផ្លាញរបស់វាមានលក្ខណៈស្រដៀង និងការប្រើប្រាស់ជីសរីរាង្គច្រើនហួសកំរិត ជាពិសេសនៅក្នុងចំការដែលសំបូរទៅដោយរុក្ខជាតិបៃតង ដូចជាដំណាំដែលដាំជាគំរបដី ឬពពួកស្មៅ ។ ដំណាំទាំងនេះវាជួយធ្វើឱ្យដីសើមហើយត្រជាក់ ដែលជួយពន្យាពេលក្នុងការដុះពន្លក។ ដង្កូវរុយចោះគ្រាប់នេះ វាស៊ីបំផ្លាញគ្រាប់ ដែលធ្វើឱ្យការដុះពន្លកមានការយឺតយ៉ាវ។ សត្វល្អិតប្រភេទនេះ វាមិនបំផ្លាញធ្ងន់ធ្ងរ

ហូតដល់កំរិតមាត់ទ្វាសេដ្ឋកិច្ចនោះទេ។ វិធានការការពារ និង កំចាត់មានដូចជា៖

-ត្រូវសំអាតគ្រាប់ពូជឲ្យបានស្អាត កុំឲ្យមានរបួស ដើម្បីការពារអំពីការងាយចោះចូលរបស់ពពួកដង្កូវរុយនេះ។

-ត្រូវថែរក្សាគ្រាប់ពូជនៅកន្លែងត្រជាក់មានសំណើម រហូតដល់រដូវកាលដាំដុះ។

៨.២.២ ចៃ (Aphid)

ក.លក្ខណៈទូទៅ



-ចៃឪឡឹកMelon Ap hid ចៃមានស្លាបមានចំនួនតិចតួច ហើយ វាមិនមាន លក្ខណៈរឹងមាំដូចពួកចៃ គ្មានស្លាបឡើយ ។ នៅពេលពេញ វ័យវាមានប្រវែងខ្លួនប្រមាណជា ១,៥ ម.ម ពួក Melon Aphid ចូលចិត្តរស់នៅក្រោមផ្ទៃស្លឹក និងពង្រីក ពូជរបស់វានៅទីនេះ។ Melon aphid មិនដូចជា aphid ផ្សេង ទៀតទេ គឺបរិមាណរបស់វាមិនថយចុះឡើយ នៅពេលដែល មានសីតុណ្ហភាពខ្ពស់។ Melon Aphid មិនត្រឹមតែបំផ្លាញទៅ លើដំណាំក្នុងអំបូរCucurbiteaប៉ុណ្ណោះទេ តែវាក៏បានបំផ្លាញទៅ លើដំណាំកប្បាស និងពួកដំណាំក្រូចផងដែរ ។ ចៃតូចៗ ដែល

មានពណ៌បៃតងទាំងនេះអាចបំផ្លាញទៅលើឪឡឹកខ្ញុំៗ និងពោត ។ ចំណុចដែលវាចូលចិត្តស៊ី គឺនៅត្រង់ផ្នែកលូតលាស់ ឬនៅត្រង់កំពូលតែម្តង ។ ពួកវាប្រមូលផ្តុំនៅខាងក្រោមស្លឹកកំពុងលូតលាស់ ដែលវាធ្វើឱ្យស្លឹកឡើងរមូរ និងរួញអង្កាញ់ ហើយវាបានបង្ហៀរនូវសារធាតុផ្អែម (honeydew) ។ ផ្លែរបស់វាចាប់ផ្តើមប្រឡាក់និងសារធាតុស្អិត ដែលបង្កលក្ខណៈងាយស្រួលឱ្យផ្សិតអាចដុះលូតលាស់ ។ ម៉្យាងទៀតវាជាភ្នាក់ងារចម្លងជំងឺវីរុស ដូចជា: Cucumber musaic, succhini-yellow និងជម្ងឺវីរុសលើឪឡឹក (Watermelon mosaic virus) ដែលជម្ងឺវីរុសទាំងនេះអាចបំផ្លាញដំណាំច្រើនជាង ការស៊ីបំផ្លាញផ្ទាល់របស់ពួកចៃទៅទៀត ។ ចំណែកពួក Aphid នៅក្នុងប្រភេទដទៃទៀតគឺវា បង្កគ្រោះថ្នាក់ស្រដៀងគ្នាជាពិសេស គឺលក្ខណៈចម្លងជំងឺ ។ ជាលទ្ធផលក្រោយការបំផ្លាញរបស់ Melon Aphid ធ្វើឱ្យដំណាំបាត់បង់កំលាំងលូតលាស់(Vigor) ហើយមានសភាពវេញៗ (stunt) ឬក៏អាចឱ្យដើមងាប់ទាំងមូលតែម្តង។

-ចៃ Rhopalosiphum maidis

Rhopalosiphum maidis ជាសត្វល្អិតម៉្យាង ដែលមានរូបរាងប្រហាក់ប្រហែលនឹងសត្វចៃ។ សត្វល្អិតនេះមានពណ៌បៃតង មានទំហំប្រមាណពី ១-២ មម និងមានអង់តែនចំនួន៦

កង់ ជើង និងកន្ទុយមានពណ៌ក្រមៅ ។ បើករណីមេចំណាស់ដែលមានដុះស្លាបក្បាល និងទ្រូងពណ៌ខ្មៅប្រផេះ។ សត្វល្អិតនេះស៊ីបំផ្លាញលើស្លឹកនៃដំណាំពោត អំពៅ និងដំណាំផ្សេងៗទៀតជាច្រើន ។ ជាទូទៅវាបំផ្លាញនៅលើស្លឹកខ្ចី គេសង្កេតឃើញមានស្នាមស្លឹកខ្លោចងាប់ និង ស្លឹក មានសភាពប្រែប្រួលរូបរាង។

ខ.វិធានការការពារ

ខ.១ វីធានការជីវសាស្ត្រ

គេអាចប្រើសត្រូវធម្មជាតិដើម្បីកំចាត់ពួក Melon Aphid បានដូចជា Lady Beetle, Hippodamia, វិធីសាស្ត្រនេះវាមានប្រសិទ្ធិភាពនៅដើមរដូវផ្ការីក។ ប៉ុន្តែការព្រលែងសត្វអណ្ដើកមាសទាំងនេះពុំសូវមានប្រសិទ្ធភាពទេ ព្រោះថាសត្វអស់ទាំងនេះវាមិនមែនសំងំនៅលើតែចំការដែលយើងព្រលែងឡើយគឺវាតែងចល័ត ពីចំការមួយទៅចំការមួយទៀត ។ ក្រៅពីអណ្ដើកមាសក៏មានសត្វប្រេដាក់ទ័រ ដទៃទៀតដែរដូចជាពពួកសត្វគ្មានស្លាប (Lacewing) និង Syrphid Larvae និងពួកឪម៉ាល់ប៉ារ៉ាស៊ីតមួយចំនួនទៀតដូចជា Lysiphlebus, Aphidius, Diaeretiella, និងក្រុម Aphilinusក៏វាអាចវាយប្រហារពួក Melon Aphidបានដែរ។ ទោះបីយ៉ាងណាក៏ដោយវិធានការជីវសាស្ត្រ មិនមានប្រសិទ្ធ

ភាពក្នុងការកាត់បន្ថយការចម្លងជម្ងឺវីរុស ដោយពួកAphidនេះដែរ។

ខ.២ វិធានការដាំដុះ

ប្រសិនជាអាចធ្វើបានគេត្រូវយកចេញ និង ដុតចោលនូវដើមណាដែលរងការបំផ្លាញដែលតែងតែកើតមានឡើងនៅក្នុងរដូវផ្ការីក វិធីនេះអាចជួយការពារចំពោះការរីករាលដាលប្រជាករនៃពពួកចៃបាន។ ការប្រើគំរបពណ៌ទឹកប្រាក់សំរាប់ការ ដាំដុះគឺមានប្រសិទ្ធភាពក្នុងការបណ្ដេញ Melon Aphid ចេញពីរុក្ខជាតិអាចកាត់បន្ថយ រឺពន្យាពេលការឆ្លងជម្ងឺវីរុសបាន។ ការប្រើគំរបធ្វើឲ្យរុក្ខជាតិលូតលាស់ដំបូងបានល្អហើយវាមាន ប្រសិទ្ធភាពរហូតដល់ចេញ ស្លឹកគ្របពាសពេញលើផ្ទៃគំរបទាំងមូល។ គំរបវាមិនបណ្ដាលឲ្យរុក្ខជាតិ ខូចខាតទេតាមពិតទៅវាជួយបង្កើនសំណើមនៅក្នុងដី និង ទប់ទល់ការហូរច្រោះសារធាតុចិញ្ចឹមចេញពីក្នុងដីដែល វាអាចជួយបង្កើនផលិតភាពដំណាំបានយ៉ាងច្រើនទៀតផង ។ ប្រសិនបើប្រជាកររបស់Melon Aphid កើនឡើងច្រើនដែលអាចផលិត Honeydewក្នុងបរិមាណច្រើន មិនត្រូវផ្ដល់ជីអាសូតលើសចំនួននោះទេ។ ចំពោះចំការដែលរងការបំផ្លាញដោយAphid គួរតែភ្ជួរឲ្យបានភ្លាមបន្ទាប់ពីប្រមូលផលរួច។

កម្ចាត់ស្មៅចង្រៃដែលមាននៅក្នុងចំការ ចំណែកឯនៅតំបន់ជុំវិញ ក៏ត្រូវសម្អាតឱ្យបានស្អាតដែរ ជាពិសេសរុក្ខជាតិដែលជាជម្រករបស់វា។

### ៨.២.៣ដង្កូវហ្វូង(Spodoptera frugiperda)





ដង្កូវហ្វូងពណ៌ខៀវក្រមៅ ក្បាលខ្មៅ ដងខ្លួនឆ្នូតលឿងព្រើងៗ និងទំហំប្រមាណប៉ុនកូនដៃ និងប្រវែង៣០-៣៥ស.ម ។ ក្បាលមានលក្ខណៈហាក់ដូចរូបអក្សរvពណ៌ស។ វដ្តជីវិត ពងដង្កូវ ដឹកឌឿ និងមេអំបៅ។ រយៈពេល២-៣ថ្ងៃ បន្ទាប់ពីបង្កាត់ពូជរួចមក មេអំបៅបានបញ្ចេញពងតូចៗចំនួនពី៥០ ដល់ ៣៥០ក្នុង១ដង ក្នុងរយៈពេលជាច្រើនថ្ងៃរហូតដល់២៥០០ជាមធ្យម ។ មេអំបៅពងដាក់នៅលើស្លឹក ផ្នែកក្រោមក្នុងរយៈពេល៣-៤ថ្ងៃ ពងញាស់ជាដង្កូវតូចៗ ហើយចាប់ផ្ដើមស៊ីបំផ្លាញ ។ ដង្កូវនេះធំ

ពេញរូបពេញរាងក្នុងរយៈពេល២-៣សប្តាហ៍ ។ ដង្កូវនេះស៊ីបំផ្លាញពេលយប់ ពេលថ្ងៃលាក់ខ្លួននៅក្នុងដី ឬកញ្ចុំស្លឹក ។ បន្ទាប់មកក៏ក្លាយជាដឹកឌឿ បង្កប់ខ្លួនក្នុងដី ហើយក្នុងរយៈពេល ៨-៩ថ្ងៃ ឬ រហូតដល់ ១៥ ថ្ងៃក្លាយជាមេអំបៅ ។ ដង្កូវស៊ីបំផ្លាញនៅផ្តុំក្នុងកញ្ចុំស្លឹកពោត ពេលជិតចេញផ្កា ។ ក្នុងករណីដង្កូវនេះស៊ីបំផ្លាញខ្លាំង អាចបណ្តាលឱ្យខូចផ្កាឈ្មោលនិងធ្វើឱ្យទិន្នផលពោតថយចុះ ។ វិធានការ ការពារ និងកំចាត់:

- ត្រូវធ្វើអនាម័យកាកសំណល់រុក្ខជាតិ
- ដាំដុះឲ្យស្របពេលគ្នា
- កម្ចាត់ស្មៅចង្រៃដែលមាននៅក្នុងចំការ ចំនែកឯនៅតំបន់ជុំវិញក៏ត្រូវសម្អាតឲ្យបានស្អាតដែរ ជាពិសេសរុក្ខជាតិដែលជាជម្រករបស់វា។
- ប្រមូលពងដង្កូវ ដឹកឌឿ កំទេចចោល
- ប្រើអន្ទាក់ភ្លើង ឬ អន្ទាក់ស្អិតដើម្បីកម្ចាត់មេអំបៅ



### ៨.២.៤ ដង្កូវចោះផ្លែពោត(Helicoverpa zea)



ដង្កូវចោះផ្លែនេះមានជើង៥គូ។ ដងខ្លួនមានពណ៌ប្រែប្រួលអាចជាពណ៌លឿងបៃតង ឬជួនកាលក្រមៅ ក្បាលពណ៌ក្រមៅ។ ដងខ្លួនឆ្នូតពណ៌សព្រើងៗ និងផ្នែកខាងក្រោមពណ៌ក្រមៅ និង ទំហំប្រមាណប៉ុនកូនដៃនិងប្រវែង៣៥-៤០សម ។ មេអំបៅពងដាក់នៅលើសក់ពោត ក្នុងរយៈពេល៣-៤ថ្ងៃ កើតជាដង្កូវតូចៗ ហើយចាប់ផ្តើមស៊ីបំផ្លាញសក់ពោត ។ បន្ទាប់មកក៏ចាប់ផ្តើមស៊ីចូលទៅក្នុងផ្លែ ហើយធំពេញរូបពេញរាងក្នុងរយៈពេល១សប្តាហ៍ ។ បន្ទាប់មកដង្កូវនេះក៏ទម្លាក់ខ្លួនមកក្នុងដី ហើយក៏ក្លាយខ្លួនជាដឹកឌឿក្នុងរយៈពេល៩-១០ថ្ងៃក៏ក្លាយជាមេអំបៅ។ វដ្តជីវិតរបស់វាក្នុងលក្ខខណ្ឌអាកាសធាតុល្អមានរយៈប្រមាណ១៥ ទៅ ២០ថ្ងៃប៉ុណ្ណោះ ។ វាចាប់ផ្តើមស៊ីបំផ្លាញផ្លែពោត ចាប់ពីពេលដង្កូវទើបនឹងញាស់រហូតដល់ដង្កូវធំ ។ បើមានការបំផ្លាញខ្លាំងអាច បណ្តាលឱ្យខូចផ្លែពោត និងបណ្តាលឱ្យថយទិន្នផលយ៉ាងខ្លាំង។

#### ៨.២.៤.១-ដង្កូវចោះផ្លែ (Fruit borer worm)

ដង្កូវប្រភេទនេះ វាបំផ្លាញដំណាំជាច្រើនប្រភេទដូចជា

ពណ៌ប្រផេះនៅខាងក្រោមស្លាបមានស្នាមបន្ទះពណ៌ត្នោតខ្មៅៗ នៅតាមគែមស្លាប ។ ដង្កូវដែលពេញរូបរាងវាមានទំហំ ៤០ម.ម ពណ៌សម្បុរវាផ្លាស់ប្តូរជានិច្ច ចាប់ពីពណ៌ត្នោតខ្មៅ ប្រែទៅជាពណ៌បៃតង ឬលឿង។ ដឹកឌឿវាមាន ទំហំ ១៥-២៥ម.ម វាមានពណ៌ក្រហមជាំ និងពណ៌ត្នោតក្រមៅ ហើយចុងពោះរបស់វាមានរាងគន្លាក់២អមសងខាងទំហំ១ម.ម ។ ដឹកឌឿរបស់ដង្កូវចោះផ្លែរស់នៅក្នុងដីចំការ ឬនៅក្នុងផ្លែប៉េងប៉ោះ នឹងក្លាយទៅជាមេអំបៅ តាមពេលកំណត់របស់វា ។ មេអំបៅទាំងនោះបានហើរត្រាច់ចរ និងពងដាក់នៅលើស្លឹក ឬគល់ វាយដាច់ពីគ្នាជាកញ្ចុំចំនួន៧៥០ពង ។ ហើយចាប់ផ្តើមញាស់ទៅតាម សីតុណ្ហភាពខុសៗ គ្នា មិនលើសពីមួយសប្តាហ៍ទេ ។ កូនដង្កូវស៊ីបំផ្លាញដំណាំប្រហែល២៨ថ្ងៃ នៅរដូវណាដែលមានសីតុណ្ហភាពខ្ពស់ ។ វាអាចបង្កើតកូនចៅបាន ២-៤ ជំនាន់ក្នុងមួយឆ្នាំ ។ កូនដង្កូវតូចៗវាទំលាក់ខ្លួនតាមសរសៃសូត្រមកបំផ្លាញដំណាំ ។ នៅពេលដែលដង្កូវពេញរូបរាងវាគ្មានសរសៃសូត្រទេ ហើយវាផ្លាស់ទីដោយជើងក្នុងការរាតត្បាតលើដំណាំ។ គេសង្កេតឃើញដង្កូវរបស់វា នៅរដូវដាំដុះពិសេសដំណាំបៃតង វាអាចស៊ីបំផ្លាញជាហ្វូងៗ ឬតែឯកឯងក៏មាន។ ប្រជាកររបស់វារីករាលដាលខ្លាំងទៅតាមបណ្តាឆ្នាំ ជាទូទៅមេចំណាស់អាចពន្យាពេលបស់វា

បាន ។ នៅពេលមេឃស្រទ្បះល្អមេអំបៅពងដាក់លើស្លឹកក្បែរៗទងផ្កា ។

វិធានការការពារ និងកំចាត់

-ត្រូវធ្វើអនាម័យកាកសំណល់រុក្ខជាតិ

-ដាំដុះឲ្យស្របពេលគ្នា

-កម្ចាត់ស្មៅចង្រៃ ដែលមាននៅក្នុងចំការចំណែកឯនៅតំបន់ជុំវិញក៏ត្រូវសម្អាតឲ្យបានស្អាតដែរ ជាពិសេសរុក្ខជាតិដែលជាជម្រករបស់វា។

-ប្រមូលពង ដង្កូវ ដឹកឌឿ កំទេចចោល

-ប្រើអន្ទាក់ភ្លើង ឬ អន្ទាក់ស្អិតដើម្បីកំចាត់មេអំបៅ

-ប្រមូលពងដង្កូវ ដឹកឌឿ កំទេចចោលប្រើអន្ទាក់ភ្លើង ឬអន្ទាក់ស្អិតដើម្បីកម្ចាត់មេអំបៅ។

### ៨.២.៥ ដង្កូវស៊ីរូងដើម (Diatraea lineolata)



លក្ខណៈរូបរាងរបស់ដង្កូវស៊ីរូងដើម គឺមានពណ៌សស្រអាប់ ឬលឿងថ្លាក្បាលខ្មៅដងខ្លួនមានអុចៗពណ៌ខ្មៅ និង ទំហំប្រមាណតូចជាងកូនដៃ និងប្រវែង២៥-៣០ស.ម។ មេអំបៅមេពងដាក់លើស្លឹកពោត បន្ទាប់

ពីរយៈពេល៤-៥ថ្ងៃ បន្ទាប់មកកកើតជាកូនដង្កូវតូចៗ ។ រយៈពេល២-៣ថ្ងៃដំបូង កូនដង្កូវស៊ីស្លឹកខ្ចី បន្ទាប់មកក៏ចាប់ផ្តើមចូលស៊ីរូងទៅក្នុងដើម ។ ដង្កូវរីកធំធាត់ពេញរូបរាងមានប្រវែងប្រមាណ២៥-៣០ស.ម រយៈពេលជីវិតជាដង្កូវ គឺពី១៥-២០ថ្ងៃ ហើយក៏ក្លាយជាដឹកឌឿ នៅក្នុងដើមពោតនោះតែម្តង ។ រយៈពេលនៃដំណាក់កាលជាដឹកឌឿគឺពី៨-១០ថ្ងៃ ហើយក៏ក្លាយជាមេអំបៅ។ ការស៊ីបំផ្លាញរបស់ដង្កូវស៊ីរូងដើម ជួនកាលមានសភាពធ្ងន់ធ្ងរគួរសមដែរ គឺអាចបំផ្លាញរហូតដល់ទៅ៩០% នៃចំនួនដើមដែលមានក្នុងចំការ ។ វាបំផ្លាញនៅស្លឹកបន្តិចបន្តួចជាសំខាន់គឺស៊ីបំផ្លាញនៅក្នុងដើមតែម្តង ។ ពេលដែលមានការបំផ្លាញខ្លាំងបណ្តាលឱ្យការលូតលាស់ផ្លែមិនសូវល្អ ។ បើករណីមានការបំផ្លាញខ្លាំង ហើយមានខ្យល់ខ្លាំងអាចបណ្តាល ឱ្យមានការបាក់ដើម ដែលកើតមានជាទូទៅនៅតាមចន្លោះថ្នាំងខាងក្រោមផ្លែ ។ បើមានការបំផ្លាញខ្លាំងអាចបណ្តាលឱ្យថយទិន្នផលយ៉ាងខ្លាំង ។

៨.២.៥.១ ដង្កូវស៊ីរូងដើម Corn borer, Corn stallk borer Order: Lepidoptera

ដង្កូវស៊ីរូងដើមប្រភេទនេះ វាបំផ្លាញរហូតដល់មានសភាពធ្ងន់ធ្ងរគួរសមដែរ។ ការបំផ្លាញនៃដង្កូវភាគច្រើនច្រើនកើតនៅតំបន់អាស៊ីរហូតដល់ទៅទ្វីបអ៊ឺរ៉ុប។ ដង្កូវមានពណ៌

លឿងស្រអាប់ក្បាលខ្មៅ ដងខ្លួនមានអុចៗពណ៌ខ្មៅទំហំប្រមាណតូចជាងកូនដៃ និង ប្រវែង៣០-៣៥ស.ម ។ វដ្តជីវិតពង ដង្កូវ ដឹកឡឿ និង មេអំបៅ ។ មេអំបៅពងដាក់លើស្លឹកពោត បន្ទាប់ពីរយៈពេល៤-៥ថ្ងៃ ញាស់ជាកូនដង្កូវតូចៗ។ ក្នុងរយៈពេល២-៣ថ្ងៃដំបូងកូនដង្កូវស៊ីស្លឹកខ្ចី បន្ទាប់មកក៏ចាប់ផ្តើមចូលស៊ីរូងទៅក្នុងដើម ហើយរីកធំធាត់ពេញរូបរាងមានប្រវែងប្រមាណ៣០-៣៥ស.ម រយៈពេលជាដង្កូវ ពី១៥-២០ថ្ងៃ ហើយក៏ក្លាយជាដឹកឡឿនៅក្នុងដើមពោតនោះតែម្តង។ រយៈពេលនៃដំណាក់កាលជាដឹកឡឿគឺពី៨-១០ថ្ងៃ ក៏ក្លាយជាមេអំបៅ។ ដំណាក់កាលបំផ្លាញពេលនៅជាដង្កូវ បំផ្លាញចាប់ពីពេលដង្កូវទើបនឹងញាស់រហូតដល់ដង្កូវធំ។ បំផ្លាញនៅស្លឹកបន្តិចបន្តួចហើយសំខាន់គឺស៊ីបំផ្លាញនៅក្នុងដើមតែម្តង។ លក្ខណៈសំគាល់នៃការបំផ្លាញ នៃដង្កូវនេះគឺយើងអាចឃើញលាមករបស់វាជ្រុះពោយលើស្លឹកមានពណ៌លឿង ។ ពេលដែលមានការបំផ្លាញខ្លាំងបណ្តាលឲ្យការលូតលាស់ផ្លែមិនសូវល្អ បើករណីមានការបំផ្លាញខ្លាំង ហើយមានខ្យល់ខ្លាំងអាចបណ្តាលឲ្យមានការបាក់ដើមដោយសារការបំផ្លាញរបស់ដង្កូវនេះ ដែលជាទូទៅនៅតាមចន្លោះថ្នាំងនៅក្រោមផ្លែ។ ការបំផ្លាញខ្លាំងអាចបណ្តាលឲ្យថយទិន្នផលយ៉ាងខ្លាំង។

វិធានការការពារនិងកម្ចាត់:

-កម្ចាត់ស្មៅចង្រៃដែលមាននៅក្នុងចំការ ចំណែកឯនៅតំបន់ជុំវិញក៏ត្រូវសម្អាតឲ្យបានស្អាតដែរ ជាពិសេសរុក្ខជាតិដែលជាជម្រករបស់វា ។

-ប្រមូលពងដង្កូវ ដឹកឡើកំទេចចោលប្រើអន្ទាក់ភ្លើង ឬអន្ទាក់ស្អិតដើម្បីកំចាត់មេអំបៅ ។

៨.២.៦ ខ្មូតខ្មៅអុចលឿងDiabrotica balteata, Diabrotica spp (Coleoptera, Chrysomelidae)



ខ្មូតខ្មៅអុចលឿងជាសត្វល្អិតតូចៗម្យ៉ាង ដែលមានរូបរាងមូលទ្រវែងនិងមានពណ៌ខ្មៅអុច ពណ៌លឿង។ សត្វល្អិតនេះ មានទំហំប្រមាណពី២ម.ម រហូតដល់១ស.ម។ សត្វល្អិតនេះជាទូទៅពងដាក់ក្នុងដីបន្ទាប់ពីញាស់ហើយវាក្លាយជាដង្កូវតូចៗពណ៌ស, ក្បាលពណ៌ខ្មៅនិងដងខ្លួនប្រវែងប្រមាណពី៦-៩ម.ម។

ជាទូទៅមេវាពងដាក់ក្នុងដី រហូតដល់ជម្រៅ១០ស.ម។ ជាទូទៅក្នុង១ឆ្នាំ វាអាចបង្កើតបាន២សត្វល្អិតនេះ ជំនាន់។៣-ស៊ីប ំផ្កាញស្លឹកពោត ក្នុងដំណាក់កាលមេពេញវ័យ ដែលធ្វើឱ្យមានស្នាមដាច់ប្រហោងនៅលើស្លឹក។ នៅពេលពងញាស់ចេញ

ជាដង្កូវវាចាប់ផ្តើមស៊ីបំផ្លាញគល់កូនពោត ហើយអាចបណ្តាលឱ្យកូនពោតនោះដាច់គល់ដួលតែម្តង។ នៅពេលដែលដង្កូវនេះស៊ីបំផ្លាញ គេសង្កេតឃើញមានលាមកវានៅជុំវិញគល់ពោត។

៨.២.៧ ទាកគូពោតCorn Flea Beetle






ទាកគូ គឺជាប្រភេទសត្វស៊ីដំណាំយ៉ាងសំខាន់ ដែលគេសង្កេតឃើញវា ស្ថិតនៅលើដំណាំជាច្រើនប្រភេទ មានដូចជាដំណាំពោត ។ វាច្រើនកើតនៅលើដំណាំពោត ដែលមានអាយុកាលពី១០-២០ថ្ងៃ។ មេចំណាស់មាន២ពណ៌ខុសគ្នា មួយមានពណ៌ខ្មៅឆ្នូតនៅពីលើខ្នងពណ៌លឿង និងមួយទៀតមានពណ៌ខ្មៅសុទ្ធ ដែលមានប្រវែង១.៥-៣ម.ម ។ វាមានភាពរហ័សរហួនក្នុងការបំលាស់ទីដោយសារលោត ឬហើរ ។ ដង្កូវទាកគូគ្រប់ប្រភេទពណ៌ស ឬពណ៌លឿងស្លេក មានជើងខ្លី។ ក្បាលដង្កូវទាកគូមានពណ៌ខ្មៅ វាស៊ីឫស និងរស់នៅក្នុងដីរយៈពេល៤-៥សប្តាហ៍ ដង្កូវមានប្រវែង៥-៦ម.ម ហើយក៏ក្លាយទៅជាដឹកឌឿនៅក្នុងដី មាន

ប្រវែង២.៥ម.ម ។ ដឹកឌៀដំបូងប្រែពណ៌ពីសទៅលឿងក្រោយមកប្រែទៅជាពណ៌ខ្មៅ។ ការស៊ីបំផ្លាញរបស់វាតិចតួចពុំសូវប៉ះពាល់ដល់ទិន្នផលឡើយ ប៉ុន្តែវាគ្រាន់តែបង្អាក់ការលូតលាស់តែប៉ុណ្ណោះ ។ វាស៊ីបណ្ដូលត្រួយខ្ចីៗ បណ្ដាលឱ្យមានស្នាមផ្លុះវេញៗនៅលើស្លឹក ។ វាច្រើនរស់នៅលើដើម និងស្លឹកពោត ហើយវាច្រើនស៊ីបំផ្លាញនៅពេលអាកាសធាតុត្រជាក់ ថ្ងៃក្ដៅវាជ្រកសំងំនៅផ្នែកខាងក្រោមនៃគល់ពោត។ ដង្កូវវាវិវត្តន៍ក្លាយជាដឹកឌៀពណ៌លឿង សំងំក្នុងដីក្រោមគល់ដំណាំ។ ការកកើតបរិមាណរបស់ពួកវាដោយសាភាពរាំងស្ងួតអូសបន្លាយ និងការប្រើប្រាស់ថ្នាំកំចាត់សត្វល្អិតច្រើន ដែលធ្វើឱ្យបាត់បង់សត្រូវធម្មជាតិរបស់ពួកវា មានដូចជាពពួកពីងពាងជាដើម។

វិធានការកំចាត់ផ្សេងៗទៀតដូចជា

-ភ្ជួរហាលដីដើម្បីសំលាប់ពង ដង្កូវ ដឹកឌៀ និង ពន្លិចទឹកមុនពេលរៀបចំដី

-បំលាស់មុខដំណាំ

-ដាក់អន្ទាក់ស្អិតចាប់យកមេចំណាស់

-ទឹកភ្លៀងក៏មានប្រសិទ្ធភាព អាចកំចាត់ទាកគូបានដែរ ដោយលាងសម្អាតសត្វទាកគូចេញពីស្លឹក និងរំខានវាមិនឲ្យពងដាក់ក្នុងដីបាន។

### ៨.២.៨ ទ្រីប ឬ មមង់ជញ្ជក់ជ័រ




ទ្រីបពេញវ័យមានពណ៌ស ជួនកាលមានពណ៌ក្រហមក្រមៅភ្លាវ ខ្លួនមានប្រវែងពី១-១.២ម.ម ។ ទ្រូងរបស់វាមានពណ៌ក្រហម អង់តែនផ្សំឡើងដោយអង្កត់ផ្ចិតខ្លីចំនួន៧កង់ ជើងពណ៌ប្រផេះ ស្លាបស្រួចទ្រវែងពណ៌លឿងភ្លាវ ។ ប្រអប់ជើងមានសណ្ឋានជាប្រអប់ជប់ ធ្វើឱ្យទ្រីបតោងជាប់បានល្អទៅលើផ្ទៃស្លឹក ។ ពងទ្រីបពណ៌សមានរាងមូលទ្រវែង ប្រវែង ០.២៦ម.ម ពងនោះមេពងដាក់ផ្ទៃកខាងខ្នងស្លឹកខាងក្រោយ។ ទ្រីបពេញវ័យលាក់ខ្លួននៅក្នុងដីបែកក្រហែង ឬនៅក្រោមកាកសំណល់រុក្ខជាតិដែលមាននៅជុំវិញចំការ។ មេទ្រីបពងដាក់ក្នុងជាលិការុក្ខជាតិបាន១០០ពង ដែលពងទាំងនោះនឹងញាស់នៅរយៈពេល៣ទៅ៥ថ្ងៃ។ កូនញាស់ចេញពីពងរស់នៅ លើស្លឹកពី ៨ទៅ១០ថ្ងៃ រួចចូលទៅក្នុងដីជំរៅ១៥សម។ វារស់នៅទីនោះរហូតក្លាយទៅជាទ្រីបពេញវ័យ ហើយមានស្លាប។ វាសំងំនៅក្នុងដីរយៈពេល២ទៅ៥ថ្ងៃ ហើយវាក៏ចេញតាមដីប្រេះក្រហែងមកវាតត្បាតដំណាំសារជាថ្មី។ ក្នុងមួយវដ្ដជីវិតទ្រីបមានរយៈ

ពេល១៥ទៅ៣០ថ្ងៃ។ ទ្រីបពេញវ័យចាប់ផ្តើមបឺតជញ្ជក់យករុក្ខរស ដែលបណ្តាលឱ្យស្លឹកក្លាយជាពណ៌លឿង ។ បន្ទាប់មកក្លាយជាពណ៌ស ឬពណ៌ក្រហមដែលធ្វើឱ្យខ្ទូរ បន្តិចបន្តួចនៅលើស្លឹក។ ពណ៌នេះវាចេះតែរាលដាលជាប់គ្នា ហើយទីបំផុតស្លឹកនោះនឹងកោងរមូលបាត់បង់ពណ៌ ពីបៃតងទៅជាប្រផេះ ហើយក្រៀមស្វិត។ ទ្រីបរាតត្បាតនៅលើស្លឹក គែមស្លឹក និងផ្កាដែលធ្វើឱ្យដំណាំក្រិនមិនលូតលាស់។

៨.២.៩ ដង្កូវដូង White grubsPhyllophaga spp (Coleoptera, Scarabaeidae, Melolonthinae)Phyllophaga spp




ជាសត្វខ្មុងតូចៗ ម្យ៉ាងដែលមានរូបរាងមូលទ្រវែង និងមានពណ៌លឿងក្រមៅ ស្លាបរឹង ។ ក្នុងដំណាក់កាលជាដង្កូវយើងស្គាល់វាជាដង្កូវដូង។ សត្វខ្មុងតូចៗ មានទំហំប្រមាណ ០.៥សមនិងបណ្តោយប្រមាណ ១សម។ សត្វល្អិតនេះជាទូទៅពងក្នុងដី ឬ លើស្មៅជាប់ដី ។ បន្ទាប់ពីញាស់ហើយ វាក្លាយជាដង្កូវដូងតូចៗពណ៌ស ក្បាលពណ៌ខ្មៅ និង ដងខ្លួនប្រវែង

ប្រមាណពី១.៥-២សម។ វាមានជើងមុខ៣គូ និងពោះវាប៉ោងធំ មានពណ៌ក្រមៅ ។ ជាទូទៅសត្វល្អិតចំណាស់ត្រូវបានទាក់ទាញដោយពន្លឺភ្លើងនៅពេលយប់។ ម្យ៉ាងទៀតសត្វខ្ទុងមេពងនៅដើមរដូវភ្លៀង។ សត្វល្អិតនេះស៊ីបំផ្លាញនៅគល់ដើមពោតក្នុងដំណាក់កាលដើមពោតនៅតូច។ នៅពេលពងញាស់ចេញជាដង្កូវដូងវាចាប់ផ្តើមស៊ីបំផ្លាញគល់កូនពោត ហើយអាចបណ្តាលឱ្យកូនពោតនោះក្រិន ឬងាប់បន្តិចម្តងៗ ហើយដួលរលួយតែម្តង ។ ចំពោះសត្វល្អិតចំណាស់វិញវាអាចស៊ីស្លឹកនៃដើមពោត ឬរុក្ខជាតិផ្សេងៗ។ ក្រៅពីដំណាំពោតវាស៊ីបំផ្លាញផងដែរដូចជាដំណាំស្រូវ សណ្តែក ដំឡូង បារាំង ប៉េងប៉ោះ ដំណាំបន្លែជាច្រើនមុខ ដំណាំកាហ្វេ និង ស្មៅដែលយើងដាំសំរាប់ជាចំណីគោ។

## ៩. ការប្រមូលផល និង ទុកដាក់

### ៩.១ ការច្រូតកាត់ប្រមូលផល

លក្ខណ:សម្គាល់ពោតទុំ:

-ផ្លែមានសំបកស្ងួតក្រៀម

-គ្រាប់រឹង ភ្លឺរលោង និងទងគ្រាប់មានពណ៌ខ្មៅ

-ដើម, ស្លឹក ស្ងួតក្រៀម

-សំណើមក្នុងគ្រាប់ប្រមាណ ២៥ %

-គ្រប់អាយុដែលអាចប្រមូលផល

ការប្រមូលផលពោតនៅប្រទេសកម្ពុជាយើង ជាទូទៅគឺយើងកាច់ដោយដៃ ហើយដឹកជញ្ជូនមកផ្ទះ បកសំបក នឹងដាក់ផ្លែពោតនោះហាល ។ ការហាលពោតត្រូវមានលានសម្រាប់ហាល ដើម្បីជៀសវាងកុំឲ្យផ្លែប៉ះប្រលាក់ដី ដែលអាចបណ្តាលឲ្យឆ្លងជម្ងឺផ្សេងៗ។ នៅតាមតំបន់តាមមាត់ទន្លេ តាមគ្រួសារខ្លះគេបកពោតហើយ គេយកផ្លែពោតទៅគរដាក់សំដិលនៅលើផ្ទះរនាប ដើម្បីឲ្យខ្យល់ចេញចូល នឹងអាចស្ងួតជាបណ្តើរៗ។ គ្រួសារខ្លះទៀតដែលមានលទ្ធភាពគេអាចធ្វើជារាន ឬ គ្រែធំៗ ដាក់ផ្លែពោតទាំងនោះគរជាគំនរ ហើយគ្រែនោះអាចបិទបើកបានដើម្បីអាចជៀសវាងកុំឲ្យត្រូវទឹកភ្លៀង។

នៅប្រទេសកំពុងអភិវឌ្ឍន៍ខ្លះ គេបានកែឆ្នៃជាឡធំៗ ដើម្បីសម្ងួតផ្លែពោតក្នុងកំរិតសីតុណ្ហភាពពី៤០-៤៥$^{o}$C បន្ទាប់ពីផ្លែពោតនោះស្ងួតហើយ (សំណើមគ្រាប់ពី១៧-២០%) គេយកផ្លែពោតទាំងនោះចូលម៉ាស៊ីនប្រឡេះគ្រាប់ ហើយគេដាក់សំងួតក្នុងឡសម្ងួតរហូតដល់សំណើមក្នុងគ្រាប់សល់ត្រឹម១៤-១៥%។ ក្នុងករណីគេអាចហាលផ្លែពោតជាលក្ខណៈធម្មតា បន្ទាប់ពីស្ងួតល្មមហើយ គេអាចយកផ្លែនោះដាក់ប្រឡេះដោយម៉ាស៊ីន រួចហើយគេដាក់ហាល រហូតដល់សំណើមក្នុងគ្រាប់សល់ត្រឹម ១៤-១៥%។

ដើម្បីសម្គាល់សំណើមក្នុងគ្រាប់ត្រឹម ១៤-១៥% គឺយើងអាចពិនិត្យឃើញគ្រាប់ពោតរឹងខ្លាំងស្រួយ ហើយពេលយើងទុកយូរមិនបែកញើស ឬ ឡើងសំណើម កាលណាយើងលូកដៃចូលក្នុងបាវគ្រាប់ពោតនោះ គឺពុំមានកម្តៅគួរអោយចាប់អារម្មណ៍ឡើយ។

ចំពោះប្រទេសជឿនលឿន គេច្រូតកាត់ពោតដោយម៉ាស៊ីន។ ម៉ាស៊ីនច្រូតពោតខ្លះគេអាចច្រូតហើយប្រឡេះតែម្តងពេលច្រូតមានរថយន្តបើកតាមត្រងយកគ្រាប់ពោត ហើយបន្ទាប់មកគេយកគ្រាប់ពោតនោះដាក់ចូលក្នុងឡសម្ងួត។ មានម៉ាស៊ីនច្រូតខ្លះ គឺត្រឹមតែច្រូត និង បកសំបក ហើយយកផ្លែនោះចូលឡសម្ងួត រួចហើយត្រូវប្រឡេះ និង បន្តសម្ងួតគ្រាប់ទៀតរហូតដល់សំណើមសល់ត្រឹម ១៤-១៥%។

ចំពោះការច្រូតកាត់ដោយម៉ាស៊ីន យើងត្រូវយកចិត្តទុកដាក់ ចំពោះលក្ខណៈរបស់ដងដើម ដោយយើងត្រូវជ្រើសរើសពូជណាដែលមានដងដើមនៅស្រស់នៅឡើយ ពេលដែលផ្លែពោតទុំ ដងដើមនៅឈរត្រង់ល្អ មិនបាក់ មិនដួល ផ្លែពោតមិនបាក់ក និង ប្រព័ន្ធឫសមាំល្អ ដើម្បីជៀសវាងកុំឲ្យដងដើមបាក់រមូលចូលក្នុងម៉ាស៊ីនច្រូត។ ការច្រូតដោយម៉ាស៊ីនជាការល្អប្រសើរគឺសំណើមក្នុងគ្រាប់ត្រឹម២៥% ។

៩.២ ការទុកដាក់គ្រាប់ពូជ

ត្រូវជ្រើសរើសពូជពោតល្អសម្រាប់ធ្វើពូជ ចំការល្អដែលផ្ដល់ផលខ្ពស់ លក្ខណៈដងដើមល្អ ដើមមិនខ្ពស់ពេក ឬ ទាបពេក ខុសពីលក្ខណៈធម្មតា ពុំមានជម្ងឺ និង សត្វល្អិតបំផ្លាញ ផ្លែពោត និង គ្រាប់ពោតពុំមានជម្ងឺ គ្រាប់ពោតមានលក្ខណៈត្រឹមត្រូវ តាមលក្ខណៈជាពូជ មិនបែក ឬ បាក់។

គ្រាប់ពូជត្រូវហាលឲ្យស្ងួតដល់សំណើមក្នុងគ្រាប់ ១៣ %។ ដើម្បីទុកដាក់គ្រាប់ឲ្យបានល្អ ជូនគេអាចលាយថ្នាំពុល ឬ សម្អាតកន្លែងដែលត្រូវទុកដាក់ ដោយបាញ់ថ្នាំសម្លាប់សត្វខ្វូត។

# ឯកសារយោង

១-សៀវភៅផលិតកម្មដំណាំពោតនៅកម្ពុជា,និពន្ធដោយ ម៉ៃយើល អិល.ខូឡេក្រូ ឆ្នាំ២០១៣

២-សៀវភៅណែនាំអំពីការគ្រប់គ្រងសត្វល្អិត និងជម្ងឺលើដំណាំបន្លែភាគ ២, គម្រោងQCAM(JICA) ឆ្នាំ២០១២

៣-សៀវភៅណែនាំ អំពីការគ្រប់គ្រងសមាសភាពចង្រៃ, គម្រោងQCAM (JICA) ឆ្នាំ២០១១

៤-បច្ចេកទេសដាំដំណាំបន្លែ, អគ្គនាយកដ្ឋានកសិកម្ម ឆ្នាំ២០១១

៥-បច្ចេកទេសដាំបន្លែសម្រាប់មន្ត្រីផ្សព្វផ្សាយ, នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង ក្រុមហ៊ុន EAST-WEST SEED INTERNATIONAL

៦-គោលការណ៍ណែនាំ សម្រាប់ធ្វើអត្តសញ្ញាណកម្ម និងការគ្រប់គ្រងជម្ងឺលើដំណាំបន្លែ IPM, ២០០៨